# អ្នកជឿលើព្រះយេស៊ូវ និងការផឹកគ្រឿងស្រវឹង

និពន្ធ និងរៀបរៀងដោយ

សមាគមស្វែងរកប្រាជ្ញាព្រះគម្ពីរព្រះយេស៊ូវ

ស្វែងរកប្រាជ្ញា ស្គាល់ព្រះជាម្ចាស់ គោរពសេចក្តីពិត

www.facebook.com/SeekingtheWisdomofJesusinKhmer

បោះពុម្ព លើកទី២

© រក្សាសិទ្ធិ ឆ្នាំ២០១៨

# មាតិកា


ជំពូក ទី១ សេចក្តីលំនាំដើម ........ ១

ជំពូក ទី២ តើព្រះគម្ពីរចែងយ៉ាងដូចម្តេចចំពោះគ្រឿងស្រវឹង ? ........ ៣

ជំពូក ទី៣ ស្រាទំពាំងបាយជូរនៅសម័យបុរាណ ........ ៧

ជំពូក ទី៤ ស្រានៅសម័យបច្ចុប្បន្ន ........ ១៥

ជំពូក ទី៥ តើព្រះគម្ពីរគាំទ្រឲ្យយើងផឹកគ្រឿងស្រវឹងសម័យបច្ចុប្បន្ននេះ ពិតមែនឬទេ ? ........ ១៨

ជំពូក ទី៦ អ្នកណាដែលវង្វេងដោយគ្រឿងស្រវឹងឈ្មោះថា គ្មានប្រាជ្ញា – *សុភាសិត ២០:១* ........ ២៨

ជំពូក ទី៧ បើខ្ញុំផឹកស្រា តើទង្វើនេះអាចនឹងនាំឲ្យបងប្អូនរួមជំនឿជំពប់ដួលដែរ ឬយ៉ាងណា ? ........ ៣២

ជំពូក ទី៨ បើខ្ញុំផឹកស្រា តើវាប៉ះពាល់ដល់ព្រះកិត្តិនាមរបស់ព្រះអម្ចាស់ យ៉ាងដូចម្តេចដែរ ? ........ ៣៦

ជំពូក ទី៩ តើស្រាអាចធ្វើឲ្យចិត្តខ្ញុំបានស្ងប់ក្សេមក្សាន្តបានដែរឬទេ ? ........ ៤១

ជំពូក ទី១០ កាតព្វកិច្ចរបស់គ្រូៗក្នុងក្រុមជំនុំចំពោះបញ្ហាស្រា ........ ៤៤

ជំពូក ទី១១ ប្រសិនបើខ្ញុំមិនផឹកស្រាទេ តើត្រូវធ្វើដូចម្តេច នៅពេលដែលគេអញ្ជើញខ្ញុំទៅចូលរួមក្នុងពិធី ? ........ ៥០

ជំពូក ទី១២ ក្តីសង្ឃឹមសម្រាប់អស់អ្នកដែលជាប់ញៀនស្រា ........ ៥៥

# *ជំពូក ទី១*
# *សេចក្តីលំនាំដើម*

គ្រីស្ទបរិស័ទភាគច្រើនធ្លាប់ផឹកស្រា តាំងពីមិនទាន់ជឿលើព្រះយេស៊ូវមកម្ល៉េះ ។ បន្ទាប់ពីជឿហើយ អ្នកខ្លះបានឈប់ផឹកតែម្តង អ្នកខ្លះនៅតែផឹកម្តងម្កាល ហើយអ្នកខ្លះទៀតបន្តផឹកច្រើនក្នុងសេរីភាព ដោយគ្មានអ្វីប៉ះពាល់ដល់មនសិការរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ គ្រីស្ទបរិស័ទភាគច្រើនមិនដែលឮការបង្រៀនអំពីការផឹកស្រាក្នុងព្រះគម្ពីរទេ ដូច្នេះ មិនដឹងប្រាកដថា យើងផឹកបាន ឬមិនបាន ។ អ្នកជឿលើព្រះយេស៊ូវដោយចិត្តស្មោះត្រង់ ប្រាកដជាចង់ដឹងពីភាពពិតនៃរឿងនេះណាស់ ។

ដោះស្រាយរឿងស្រានេះដោយពឹងលើប្រាជ្ញារបស់ខ្លួន ពិតជាពិបាកខ្លាំងណាស់ ពីព្រោះវាជាបញ្ហាដ៏ចង្អៀតចង្អល់ ។ ម្យ៉ាង ស្រុកខ្មែរបានយកពុទ្ធសាសនាជាសាសនារបស់ជាតិ ហើយក្នុងពុទ្ធសាសនានោះបានបង្រៀនថា បុគ្គលណាដែលមានចិត្តបរិសុទ្ធ នឹងចង់គោរពប្រតិបត្តិតាមឱវាទល្អៗនៅក្នុងសាសនា ដូចជា «គប្បីវៀរចាកការសេព (ផឹក) គ្រឿងស្រវឹងគ្រប់ប្រភេទ» ។[១] ដូច្នេះ បើសិនជាគ្រីស្ទបរិស័ទយើងផឹកស្រា នោះអ្នកកាន់ពុទ្ធសាសនានឹងមើលមកយើងថា ជាពួកអសីលធម៌ ។ យ៉ាងនេះ គឺយើងបានបន្ថុះបង្អាប់ដល់ព្រះនាមដ៏វិសុទ្ធរបស់ព្រះគ្រីស្ទ ដោយនាំឲ្យអ្នកមិនជឿរិះគន់ដាក់យើង ក្នុងឈ្មោះជាអ្នកបម្រើរបស់ព្រះអង្គ ។

ម្យ៉ាងវិញទៀត ក្នុងសង្គមដែលនៅជុំវិញខ្លួនរាល់ថ្ងៃ មានមនុស្សជាច្រើនដែលចូលចិត្តផឹកឲ្យស្រវឹង ។ ប្រសិនបើយើងមិនព្រមផឹកស្រារួមជាមួយនឹងពួកគេទេ

---

(១) សីល ទី៥ ក្នុងពុទ្ធសាសនា យោងតាមសៀវភៅ *ព្រះពុទ្ធទ្រង់បង្រៀនអ្វី?* និពន្ធដោយលោក លីន កុសល បោះពុម្ពឆ្នាំ ២០១១ ទំព័រ ២០៣ ។

នោះមុខតែត្រូវគេចំអកឡកឡឺយដាក់យើង ឬប្រហែលជាគេនឹងលែងរាប់អានយើងតែម្តង ។ តើគួរឲ្យយើងជ្រើសយកផ្លូវមួយណា ?

ថ្វីបើការសំរេចចិត្តនេះអាស្រ័យទៅលើបុគ្គលម្នាក់ៗដោយខ្លួនឯងក៏ដោយ ក៏យើងដឹងប្រាកដហើយដែរថា ព្រះជាម្ចាស់ «**ទ្រង់ជំនុំជំរះ តាមការដែលគេប្រព្រឹត្តរៀងខ្លួន ឥតរើសមុខអ្នកណា**» ( *១ពេត្រុស ១:១៧* ) ។ ដូច្នេះ យើងត្រូវតែស្គាល់អំពីព្រះហឫទ័យរបស់ព្រះអង្គយ៉ាងច្បាស់លាស់ ដើម្បីកុំឲ្យជាប់មានទោសនៅថ្ងៃជំនុំជំរះ ។ សំណួរដែលសំខាន់ជាងគេ គឺថា *តើព្រះជាម្ចាស់ ទ្រង់សព្វព្រះហឫទ័យយ៉ាងណា?* បើយើងចង់សម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គពិតមែន ទុកដូចជាអ្នកបម្រើដ៏ស្មោះត្រង់ នោះត្រូវតែលះបង់បំណងចិត្តរបស់ខ្លួនជាមុនសិន ឲ្យបានផ្តោតអារម្មណ៍យ៉ាងហ្មត់ចត់ទៅលើព្រះបន្ទូលរបស់ទ្រង់វិញ ដោយចិត្តទន់ភ្លន់ ដែលអាចទទួលការបង្គាប់ពីព្រះអង្គបាន ។ ស្គាល់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់កាន់តែច្បាស់ នឹងមានប្រាជ្ញាមកពីទ្រង់កាន់តែច្រើនដែរ នោះអាចនឹងដោះស្រាយបញ្ហាស្រាដោយសារប្រាជ្ញាឲ្យបានចម្រើនសិរីរុងរឿងរបស់ព្រះអង្គ និងទទួលការសរសើរពីទ្រង់នៅថ្ងៃជំនុំជំរះ ។

ក្នុងសៀវភៅនេះ យើងនឹងពិនិត្យមើលវគ្គគម្ពីរដ៏សំខាន់ៗមួយចំនួន ដែលចែងអំពីស្រា រួមមានវគ្គខ្លះដែលបង្ហាញថា ស្រាទំពាំងបាយជូរអាចជាព្រះពរម៉្យាង និងវគ្គខ្លះទៀតដែលប្រាប់អំពីគ្រោះថ្នាក់នៃគ្រឿងស្រវឹង ។ យើងនឹងពន្យល់អំពីរបៀបដែលគេធ្វើ និងប្រើប្រាស់ស្រាទំពាំងបាយជូរនៅសម័យដើម ដើម្បីយល់អំពីអត្ថន័យរបស់វគ្គគម្ពីរទាំងនោះឲ្យបានជិតដិតដល់ ។ មួយវិញទៀត យើងនឹងពិចារណាអំពីកាតព្វកិច្ចរបស់អ្នកជឿលើព្រះយេស៊ូវចំពោះការប៉ះពាល់ និងលទ្ធផលនៃការផឹកគ្រឿងស្រវឹងដល់សង្គមមនុស្សនាបច្ចុប្បន្នកាលនេះផងដែរ ។ រួច ទើបយើងអាចយកសេចក្តីដែលរកឃើញក្នុងព្រះគម្ពីរចំពោះស្រា មកអនុវត្តក្នុងជីវិតរស់នៅរាល់ថ្ងៃរបស់យើងបានយ៉ាងត្រឹមត្រូវ ដែលគាប់ដល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។

## *ជំពូក ទី២*
## *តើព្រះគម្ពីរចែងយ៉ាងដូចម្ដេចចំពោះគ្រឿងស្រវឹង ?*

មានវគ្គគម្ពីរជាច្រើន ដែលបង្ហាញឲ្យយើងឃើញច្បាស់លាស់ថា ការស្រវឹងស្រា វាតែងតែជំទាស់ទៅនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ណាស់ ។ សូមពិនិត្យមើលវគ្គគម្ពីរខាងក្រោមនេះ ដោយផ្ដោតអារម្មណ៍ក្នុងការស្វែងយល់អំពីព្រះហឫទ័យរបស់ព្រះអង្គសិនចុះ ៖

វេទនាដល់ពួកអ្នកដែលប៉ិនប្រសប់នឹងផឹកស្រាទំពាំងបាយជូរ និងអ្នកដែលខ្លាំងពូកែក្នុងការលាយគ្រឿងស្រវឹង ។

*អេសាយ ៥:២២*

ស្រាទំពាំងបាយជូរ នោះរមែងដកយោបល់ចេញ ។

*ហូសេ ៤:១១*

ឯស្រាទំពាំងបាយជូរ ជារបស់បញ្ឆោតមើលងាយ
ហើយគ្រឿងស្រវឹងបង្កើតការឡូឡា
អ្នកណាដែលវង្វេងដោយគ្រឿងទាំង២នោះ
ឈ្មោះថា គ្មានប្រាជ្ញា ។

*សុភាសិត ២០:១*

មិនគួរឲ្យពួកស្ដេចបានសោយស្រាទំពាំងបាយជូរ គឺមិនគួរសោះឡើយ
ក៏មិនគួរឲ្យអ្នកដែលជាកំពូលប្រាជ្ញាគ្រឿងស្រវឹងដែរ
ក្រែងផឹកទៅហើយ នោះភ្លេចបញ្ញត្តច្បាប់

ហើយបង្វែរសេចក្ដីយុត្តិធម៌ពីមនុស្សដែលកើតទុក្ខវេទនាចេញ ។

*សុភាសិត ៣១:៤-៥*

កុំឲ្យនៅកណ្ដាលពួកអ្នកប្រមឹកស្រា ឬក្នុងពួកល្មោភស៊ីឡើយ

ដ្បិតមនុស្សប្រមឹក និងមនុស្សល្មោភនឹងទៅជាក្រ ។

*សុភាសិត ២៣:២០-២១*

តើអ្នកណាមានសេចក្ដីពិបាកចិត្ត តើអ្នកណាកើតទុក្ខព្រួយ

តើអ្នកណាមានសេចក្ដីទាស់ទែងគ្នា តើអ្នកណាត្អូញត្អែរ

តើអ្នកណាត្រូវរបួសឥតហេតុ តើអ្នកណាមានភ្នែកក្រហម

គឺជាពួកអ្នកដែលអង្គុយផឹកស្រាជាយូរ

ឯពួកអ្នកដែលស្វែងរកស្រាលាយនោះឯង

កុំឲ្យមើលស្រាទំពាំងបាយជូរ ក្នុងកាលដែលមានពណ៌ក្រហម

គឺក្នុងកាលដែលព្រួចពពុះនៅក្នុងកែវ

ហើយហូរចុះទៅដោយស្រួលនោះឡើយ

ដ្បិតដល់ចុងបំផុតនឹងចឹកដូចជាពស់វិញ

ហើយអុចដូចជាពស់ហានុមានផង

ភ្នែកឯងនឹងឃើញស្រីដទៃ

ហើយចិត្តឯងនឹងពោលសេចក្ដីខូចអាក្រក់ដែរ

អើ ឯងនឹងបានដូចជាមនុស្សដែលដេកនៅកណ្ដាលសមុទ្រ

ឬដូចជាមនុស្សដែលដេកនៅលើចុងដងក្ដោង

ឯងនឹងថា គេបានវាយអញ តែអញមិនបានឈឺសោះ

គេបានសំពងអញ តែអញមិនដឹងទេ

**តើអញនឹងភ្ញាក់ឡើងវិញដល់កាលណាហ្ន៎**
**អញនឹងទៅរកផឹកទៀត ។**

*សុភាសិត ២៣:២៩-៣៥*

ការសង្ខេបអំពីសេចក្តីខាងលើនេះ គឺព្រះគម្ពីរបានប្រាប់យើងយ៉ាងច្បាស់លាស់ថា ស្រារមែងដកយោបល់ល្អចេញពីមនុស្ស ហើយបញ្ឆោតពួកគេឲ្យវង្វេងពីមាគ៌ានៃប្រាជ្ញា រួចដើរទៅតាមផ្លូវល្ងីល្ងើវិញ រួមទាំងទៅប្រព្រឹត្តអំពើបាបគ្រប់បែបយ៉ាងទៀតផង ។ ជីវិតរបស់អ្នកដែលវង្វេងដោយសារស្រានឹងវេទនាណាស់ ពីព្រោះពោរពេញទៅដោយទុក្ខលំបាកជាច្រើន ដែលគេបង្ករឡើងពីលើខ្លួនគេ ។ គេមិនត្រឹមតែធ្វើឲ្យពិបាកដល់ខ្លួនឯងប៉ុណ្ណោះទេ គឺគេថែមទាំងធ្វើឲ្យមានភាពវឹកវរក្នុងសង្គមទៀតផង ហើយនាំឲ្យមនុស្សជាច្រើនរួមវេទនាជាមួយនឹងគេដែរ ។ មិនថាត្រឹមតែជនប្រមឹកតែព្រះគម្ពីរចែងបែបនេះចំពោះ «**អ្នកណាដែលវង្វេង**» ដោយគ្រឿងស្រវឹង ។

រីឯអ្នកផឹកស៊ីស្រវឹងជាទំលាប់ គេគ្មានសង្ឃឹមថា ព្រះអម្ចាស់នឹងសង្គ្រោះគេឡើយ លុះត្រាតែគេកែប្រែចិត្តជាមុនសិន ពីព្រោះ «**ពួកប្រមឹក...មិនដែលបានគ្រងនគរព្រះទុកជាមរដកឡើយ**» ( *១កូរិនថូស ៦:១០* ) ។ ទីបំផុត ក្នុងព្រះគម្ពីរមានចែងទុកយ៉ាងច្បាស់លាស់ថា ព្រះជាម្ចាស់ ទ្រង់ហាមប្រាមមិនឲ្យប្រជារាស្ត្រដ៏បរិសុទ្ធរបស់ព្រះអង្គស្រវឹងស្រាជាដាច់ខាតតែម្តង ៖ «**កុំឲ្យស្រវឹងស្រា**» ( *អេភេសូរ ៥:១៨* ) ។

ថ្វីបើព្រះគម្ពីរចែងទុកមកចំពោះការស្រវឹងយ៉ាងខ្លាំងដូច្នេះក៏ដោយ ក៏គ្រីស្ទបរិស័ទខ្លះនៅតែចង់ផឹកគ្រឿងស្រវឹង ។ ដើម្បីបង្ហាញថា យើងមានសិទ្ធិសេរីភាពក្នុងការផឹកស្រា គេសំអាងទៅលើពាក្យដូចខាងក្រោមនេះជាដើម ៖

- ព្រះគម្ពីរមិនដែលហាមថា «កុំឲ្យផឹកស្រាជាដាច់ខាត» ទេ គឺព្រះគម្ពីរគ្រាន់តែហាមថា «**កុំឲ្យស្រវឹងស្រា**» ប៉ុណ្ណោះ ( *អេភេសូរ ៥:១៨* ) ។

- ក្នុងព្រះគម្ពីរបានចាត់ទុកស្រាទំពាំងបាយជូរយ៉ាងបរិបូរណ៍ថា ជាព្រះពរដែលព្រះជាម្ចាស់ប្រទានមកមនុស្សទេតើ ( *ចោទិយកថា ៧:១៣ និង១១:១៤* ) ។
- សូម្បីតែព្រះយេស៊ូវផ្ទាល់ក៏បានធ្វើស្រាទំពាំងបាយជូរ រួមទាំងសោយវាទៀតផង ( *យ៉ូហាន ២ និងម៉ាថាយ ១១:១៩* ) ។
- សាវ័កប៉ុលបានបង្គាប់ឲ្យធីម៉ូថេផឹកស្រាទំពាំងបាយជូរ ( *១ធីម៉ូថេ ៥:២៣* ) ។

ដូច្នេះ គេសន្និដ្ឋានថា «ផឹកស្រាបាន តែកុំឲ្យស្រវឹង» ដោយពុំសូវបានពិចារណាប៉ុន្មានទេ ។ ក៏ប៉ុន្តែ ការរកហេតុផលបែបនេះផ្អែកទៅលើការយល់ច្រឡំដែលបង្កឡើងដោយការគិតស្មានមិនត្រឹមត្រូវថា ស្រាដែលមានលក់សព្វថ្ងៃនេះ និងទំលាប់របស់មនុស្សក្នុងការផឹកវា ប្រហែលជាមិនសូវខុសគ្នាពីសម័យគម្ពីរប៉ុន្មានទេ ។ ដូច្នេះ គេគិតថា បើព្រះគម្ពីរអនុញ្ញាតឲ្យមនុស្សនៅសម័យដើមផឹកស្រា នោះព្រះគម្ពីរប្រាកដជាគាំទ្រឲ្យយើងផឹកស្រានៅសម័យបច្ចុប្បន្ននេះផងដែរ តែសេចក្ដីនេះមិនពិតឡើយ ។ ពេលយើងសិក្សាស្រាវជ្រាវអំពីស្រាបុរាណ នោះយើងឃើញថា របៀបធ្វើ និងការប្រើប្រាស់ស្រា រួមទាំងគោលបំណង និងទំលាប់របស់មនុស្សជាទូទៅក្នុងការផឹកវាគឺខុសគ្នាពីសម័យបច្ចុប្បន្ននេះដាច់ស្រឡះ ។ បើយើងចង់យល់អំពីសេចក្ដីទាំងប៉ុន្មានដែលព្រះគម្ពីរចែងចំពោះស្រាយ៉ាងជិតដិតដល់ គឺជាស្រាបុរាណដែលគេបានធ្វើនៅសម័យដើម នោះយើងចាំបាច់ត្រូវតែដឹងជាមុនសិនថា *ស្រាដែលគេបានធ្វើនៅសម័យនោះ តើវាយ៉ាងដូចម្ដេចដែរ?* ដូច្នេះ ក្នុងជំពូក ទី៣ យើងនឹងពិនិត្យមើលអំពីស្រានៅសម័យគម្ពីរ លុះ ក្នុងជំពូក ទី៤ យើងនឹងពិនិត្យមើលអំពីស្រានៅពេលបច្ចុប្បន្នដើម្បីធ្វើការប្រៀបធៀប ។ រួច ទើបយើងអាចអនុវត្តតាមសេចក្ដី ដែលរកឃើញក្នុងព្រះគម្ពីរចំពោះស្រាបានត្រឹមត្រូវ ។

# *ជំពូក ទី៣*
# *ស្រាទំពាំងបាយជូរនៅសម័យបុរាណ*

បើយើងចង់និយាយថា “មើល ព្រះគម្ពីរអនុញ្ញាតឲ្យមនុស្សផឹកស្រា” នោះក៏ត្រូវសួរដែរថា តើ*អ្នកណា* ដែលព្រះគម្ពីរអនុញ្ញាតឲ្យផឹកស្រា ? តើ*ស្រារបៀបណា* ដែលអនុញ្ញាតឲ្យផឹក ? ហើយ តើដោយសារ*មូលហេតុអ្វី* ដែលអាចនឹងប្រើប្រាស់ស្រាបាន ? កាលណាព្រះគម្ពីរចែងអំពីស្រា គឺមិនមែនចែងចំពោះស្រាបៀរ ឬស្រាខ្លាំងដូចជាស្រាវីស្គី ដែលមានលក់នៅក្នុងទីផ្សារសព្វថ្ងៃនេះឡើយ ហើយ នៅសម័យគម្ពីរមនុស្សក៏មិនបានផឹកស្រាដោយមូលហេតុដូចមនុស្សដែលផឹកសព្វថ្ងៃនេះដែរ ។ ព្រះគម្ពីរចែងចំពោះស្រាបុរាណ ដែលគេបានធ្វើនៅសម័យបុរាណ ដោយរបៀបបុរាណ ហើយគេបានប្រើប្រាស់វាតាមទំលាប់បុរាណផងដែរ ។ តើអ្នកគិតថា ស្រាបុរាណខុសគ្នាពីស្រាសម័យបច្ចុប្បន្នដែរឬទេ ? បើសិនជាខុសគ្នាមែន តើខុសគ្នាត្រង់ណា ? នៅក្នុងជំពូកនេះ យើងនឹងឆ្លើយសំណួរទាំងអស់ខាងលើ ។

## *របៀបធ្វើស្រាទំពាំងបាយជូរនៅសម័យបុរាណ*

នៅក្នុងសម័យបុរាណ មិនទាន់មានបច្ចេកទេសបិតស្រា ដើម្បីបង្កើនជាតិអាល់កុល ឬរោងចក្រដែលមានម៉ាស៊ីនធំៗសម្រាប់ធ្វើស្រា ដូចមានសព្វថ្ងៃនេះនៅឡើយទេ តែពួកគេបានធ្វើស្រាទំពាំងបាយជូរជាប្រភេទកសិកម្ម នៅក្នុងចំការទំពាំងបាយជូរ ។ ពេលបេះ និងប្រមូលផ្លែទំពាំងបាយជូរហើយ ពួកគេបានបញ្ជាន់វានៅក្នុងអាង ហើយទុកទឹកផ្លែឈើក្នុងពាង ឬថង់ស្បែកយ៉ាងយូរ ឲ្យឡើងជូរតាមធម្មជាតិខ្លួនឯង ទើបវាមានរសជាតិឆ្ងាញ់ និងមានជាតិអាល់កុលខ្លះផងដែរ ។ ពួកគេបេះ

ផ្លែទំពាំងបាយជូរក្នុងមួយឆ្នាំបានតែមួយដងទេ ដូច្នេះ ពួកគេត្រូវមានវិធីសាស្ត្រមួយដើម្បីរក្សាទុកទឹកផ្លែទំពាំងបាយជូរឲ្យបានយូរ យ៉ាងហោចណាស់ រហូតដល់រដូវប្រមូលផលនៅឆ្នាំបន្ទាប់ទៀត ។ ប្រសិនបើមិនបានធ្វើស្រាទំពាំងបាយជូរទេ នោះពួកគេត្រូវខាតបង់ផលប្រយោជន៍នៃភោគផលទាំងអស់ ពីព្រោះវានឹងខូច ដោយក្លាយទៅជាទឹកខ្មេះ ដែលមនុស្សមិនអាចផឹកបានទេ ។[២] មួយវិញទៀត ធ្វើទឹកផ្លែឈើដែលគ្មានជាតិអាល់កុលមិនកើតទេ ពីព្រោះវាចាប់ផ្តើមឡើងជូរតាំងពីខណៈពេលបញ្ជាន់ ហើយ នៅគ្រានោះមិនទាន់មានបច្ចេកទេសសម្រាប់បង្ខាំងដំណើរឡើងជូរនៅឡើយដែរ ។[៣] ប៉ុន្តែ បើធ្វើស្រាទំពាំងបាយជូរ នោះវាមិនខូចទេ ពីព្រោះជាតិអាល់កុលអាចរក្សាជីវជាតិក្នុងវាបានរាប់ឆ្នាំ ហើយមនុស្សក៏អាចប្រើប្រាស់វាបានរាប់ឆ្នាំផងដែរ ។ ដូច្នេះ ពួកគេបានធ្វើស្រាទំពាំងបាយជូរតាមរបៀបធម្មជាតិ ដោយគោលបំណងធំបំផុត គឺរក្សាទុកភោគផលកសិកម្មដ៏បរិបូរណ៍របស់ស្រុកគេឲ្យបានយូរ ហើយពួកគេគ្មានបច្ចេកទេសទំនើបសម្រាប់បង្ខាំងដំណើរឡើងជូរ ឬបច្ចេកទេសទំនើបអ្វីសម្រាប់បិតស្រាឲ្យកើនជាតិអាល់កុលនោះទេ ។

## *ការប្រើប្រាស់ស្រាទំពាំងបាយជូរនៅសម័យបុរាណ*

នៅសម័យបុរាណ ស្រាទំពាំងបាយជូរ និងស្រាធ្វើពីភោគផលផ្សេងៗទៀតគឺជាគ្រឿងផ្សំ ហើយ ជាប្រក្រតីមនុស្សមិនដែលផឹកស្រាដោយមិនលាយជាមួយនឹងទឹកនោះឡើយ ។ ក៏ប៉ុន្តែ ប្រសិនបើពួកគេលាយស្រាជាមួយនឹងទឹក នោះវានឹងផ្តល់អត្ថប្រយោជន៍ជាច្រើនក្នុងការរស់នៅប្រចាំថ្ងៃសម្រាប់គ្រប់ៗគ្នា ។

---

(២) យោងតាមសៀវភៅ *Christians and Alcohol* និពន្ធដោយលោក Randy Jaeggli បោះពុម្ពឆ្នាំ ២០១៤ ទំព័រ ១២ លេខយោង ទី១ និងទំព័រ ៤១ ។

(៣) យោងតាមសៀវភៅ *Christians and Alcohol* ទំព័រ ១២ ។

រហូតមកដល់សតវត្សរ៍ ទី១៩ នៅមិនទាន់មានបច្ចេកទេសសម្រាប់ច្រោះទឹកស្អាតដូចមានសព្វថ្ងៃនេះនៅឡើយទេ ដូច្នេះ នៅសម័យគម្ពីរ មនុស្សបានប្រើប្រាស់ស្រាទំពាំងបាយជូរ ដើម្បីសំអាតទឹកពិសា ។ ជួនកាល ពួកគេត្រូវផឹកទឹកដែលមកពីប្រភព ឬកន្លែងទុកទឹកមិនស្អាត ដូចជាអណ្តូង ឬពាងជាដើម ហើយ បើពួកគេផឹកទឹកមិនស្អាតបែបនេះ នោះក៏ត្រូវកើតជំងឺ ដូចយើងសព្វថ្ងៃនេះដែរ ។[៤] នេះប្រហែលជាមូលហេតុ ដែលលោកធីម៉ូថេឈឺក្រពះក្នុងកណ្ឌ១ធីម៉ូថេ ៥:២៣ ពីព្រោះតាមមើលលោកចង់ផឹកទឹកតែប៉ុណ្ណោះ ។ នៅគ្រានោះ ពុំមានលក់ទឹកសុទ្ធទេ ប៉ុន្តែ បើសិនជាពួកគេលាយស្រាទំពាំងបាយជូរជាមួយនឹងទឹកមិនស្អាត នោះជាតិអាល់កុលក្នុងស្រានឹងក្លាយទៅជាថ្នាំរំងាប់មេរោគក្នុងទឹក ។ ដូច្នេះ វិធីលាយស្រាទំពាំងបាយជូរជាមួយនឹងទឹកនេះ គឺជាការចាំបាច់ដើម្បីសំអាតទឹក ឲ្យបានការពារសុខភាពរបស់ពួកគេ ។

នៅសម័យបុរាណ ស្រាទំពាំងបាយជូរក៏មានចំណែកដ៏សំខាន់មួយក្នុងការចិញ្ចឹមជីវិតរបស់មនុស្សជាតិ ។ មនុស្សគ្រប់ៗគ្នាធ្លាប់បរិភោគស្រាទំពាំងបាយជូរលាយជាមួយនឹងទឹកបន្តិច និងនំប៉័ង ដើម្បីបំពេញតំរូវការជាប្រចាំថ្ងៃនៃរូបរាងកាយរបស់ពួកគេ ។[៥] ស្រាទំពាំងបាយជូរលាយជាមួយនឹងទឹកបានផ្គត់ផ្គង់នូវថាមពល និងជីវជាតិចិញ្ចឹមដល់សរីរាង្គកាយរបស់ពួកគេ រួមទាំងផ្តល់ជាតិទឹកជាច្រើនផងដែរ ដូចជាទឹកផ្លែឈើ ឬភេសជ្ជៈផ្សេងៗទៀត ដែលយើងផឹកសព្វថ្ងៃនេះ ។ សូម្បីតែកូនក្មេងតូចក៏ត្រូវការស្រាទំពាំងបាយជូរ ដើម្បីចិញ្ចឹមជីវិតរបស់ពួកគេ ដូចអាហារដែរ ។

---

(៤) យោងតាមឯកសារ “Wine as a Table-Drink in the Ancient World” ដោយលោក Everett Ferguson ក្នុងទស្សនាវដ្តី *Restoration Quarterly* លេខ ទី១៣ បោះពុម្ពឆ្នាំ ១៩៧០ ទំព័រ ១៤៣ ។

(៥) មានឧទាហរណ៍ច្រើនក្នុងព្រះគម្ពីរ ដូចជាលោកុប្បត្តិ ១៤:១៨ ចៅហ្វាយ ១៩:១៩ ហើយនិង ១សាំយូអែល ១៦:២០ និង២៥:១៨ ជាដើម ។

នៅក្នុងកណ្ឌបរិទេវ ២:១១-១២ យើងឃើញថា ពួកក្មេងតូចបានដួលសន្លប់នៅគ្រា ដែលស្រុកខ្វះខាតទាំងអង្គរសាលី និងស្រាទំពាំងបាយជូរផង ។ នៅសម័យឥឡូវនេះ គ្មានឪពុកម្តាយល្អណាម្នាក់ ដែលហ៊ានឲ្យស្រាទៅកូនតូចរបស់ខ្លួនផឹកនោះឡើយ ! ប៉ុន្តែ នៅសម័យគម្ពីរ ការផឹកស្រាទំពាំងបាយជូរដែលធ្វើរបៀបបុរាណ ហើយលាយ ជាមួយនឹងទឹក ជាធម្មតាមិននាំឲ្យទៅជាស្រវឹងទេ ។ ផ្ទុយទៅវិញ វាបានជួយចិញ្ចឹម ដល់ជីវិតរបស់ពួកគេគ្រប់ៗគ្នា តាំងពីក្មេងទៅដល់ចាស់ ។

លើសពីនេះទៅទៀត ស្រាទំពាំងបាយជូរបានជួយឲ្យមនុស្សអាចរស់នៅក្នុង តំបន់ស្ងួតហួតហែង ដែលពុំសូវមានទឹកភ្លៀង ឬមិនមានប្រភពទឹកនៅក្បែរៗនោះ ដូចជាវាលរហោស្ថានជាដើម ។ ក្នុងកណ្ឌ២សាំយូអែល ១៦:១-២ លោកស៊ីបាបាន ថ្វាយស្រាទំពាំងបាយជូរដល់ស្តេចដាវីឌសោយ ព្រមទាំងឲ្យទៅកងទ័ពរបស់ទ្រង់ផឹក ដែរ ដើម្បីជួយជាកម្លាំងដល់ «**អ្នកណា ដែលហេវនៅទីរហោស្ថាន**» ។ បើផឹកស្រា សម័យបច្ចុប្បន្ន ដែលមានជាតិអាល់កុលខ្លាំងជាង ហើយមិនបានលាយជាមួយនឹង ទឹក ក្នុងករណីដែលកំពុងតែហេវហត់នៅទីក្តៅ ហើយខ្សោះជាតិទឹកក្នុងខ្លួនយ៉ាងដូច្នេះ នោះវានឹងធ្វើទុក្ខកាន់តែខ្លាំងឡើង រហូតដល់ស្លាប់ក៏មានដែរ ពីព្រោះវាបានកាត់បន្ថយ ជាតិទឹកក្នុងខ្លួនបន្ថែមទៀត ។ ក៏ប៉ុន្តែ បើផឹកស្រាទំពាំងបាយជូរបុរាណជាគ្រឿងផ្សំ លាយជាមួយនឹងទឹក នោះវាអាចផ្តល់ជាតិទឹកជាច្រើន ជីវជាតិចិញ្ចឹមរូបរាងកាយ និងថាមពលដល់មនុស្សហេវហត់បាន ។[៦]

មនុស្សនៅសម័យដើមក៏បានប្រើស្រាទំពាំងបាយជូរជាថ្នាំឱសថដែរ ។[៧]

(៦) យោងតាមសៀវភៅ *Christians and Alcohol* ទំព័រ ៧៣ លេខយោង ទី៤ ។

(៧) យោងតាមឯកសារ "Wine-Drinking in New Testament Times" ដោយលោក Robert H. Stein ក្នុងទស្សនាវដ្តី *Christianity Today* បោះពុម្ពខែ មិថុនា ឆ្នាំ ១៩៧៥ ទំព័រ ៩-១០ ។

ក្នុងកណ្ឌ១ធីម៉ូថេ ៥:២៣ សាវ័កប៉ុលបានផ្ដែផ្ដាំលោកធីម៉ូថេថា «**កុំឲ្យផឹកទឹកតែប៉ុណ្ណោះ ត្រូវឲ្យផឹកស្រាទំពាំងបាយជូរបន្តិចផង ដោយព្រោះក្រពះអ្នក និងរោគដែលអ្នកមានជាញយៗ**» ។ សម្ដីរបស់លោកប៉ុលនេះបញ្ជាក់ថា សូម្បីតែក្នុងករណីបែបនេះ ដែលពួកគេប្រើប្រាស់វាជាថ្នាំ ក៏ពួកគេមានទំលាប់លាយស្រាទំពាំងបាយជូរជាមួយនឹងទឹកដែរ ។ ក្នុងព្រះគម្ពីរមានការប្រើប្រាស់ស្រាទំពាំងបាយជូរជាថ្នាំឱសថផ្សេងៗទៀត ដូចជា ថ្នាំកាត់បន្ថយការឈឺចាប់ (*សុភាសិត ៣១:៦ និងម៉ាកុស ១៥:២៣*) ឬថ្នាំលាងរបួស (*លូកា ១០:៣៤*) ជាដើម ។

សរុបអស់ទាំងសេចក្ដីខាងលើនេះមក យើងឃើញថា ស្រាទំពាំងបាយជូរបុរាណ គឺជារបស់ដ៏សំខាន់មួយក្នុងជីវិតរស់នៅជាប្រចាំថ្ងៃរបស់មនុស្ស ។ វាមិនមែនជារបស់ប្រណិត ដែលពួកគេប្រើប្រាស់សម្រាប់តែឱកាសពិសេសទេ ហើយ ជាធម្មតាពួកគេក៏ពុំបានផឹកវាដើម្បីឲ្យស្រវឹងនោះដែរ មិនដូចជារបៀបនៃការប្រើប្រាស់ស្រាដែលមានលក់សព្វថ្ងៃនេះឡើយ ។ ផ្ទុយទៅវិញ សម្រាប់ពួកគេ ស្រាទំពាំងបាយជូរគឺជារបស់ដ៏សំខាន់មួយ ដែលត្រូវការជារៀងរាល់ថ្ងៃ ទោះជាក្មេង ឬចាស់ ក្រ ឬមានដើម្បីទ្រទ្រង់ និងការពារសុខភាពរបស់ពួកគេគ្រប់ៗគ្នា ។ បើនិយាយអំពីភាពចាំបាច់របស់ស្រា ក្នុងព្រះគម្ពីរ យើងពិនិត្យឃើញថា ពួកគេបានចាត់ទុកស្រាទំពាំងបាយជូរប្រហែលជាសំខាន់ស្មើនឹងអង្ករសាលីដែរ ។ ជាក់ស្ដែង ក្នុងទំលាប់ប្រើប្រាស់ស្រាទំពាំងបាយជូររបស់ពួកគេ គឺដោយលាយជាមួយនឹងទឹកជាគ្រឿងផ្សំ ហើយបរិភោគវាជាមួយនឹងនំប៉័ងប្រចាំថ្ងៃ វាជួយផ្ដល់កម្លាំងឲ្យមនុស្សឈរដោយសុខភាពល្អរឹងមាំ មិនមែនធ្វើឲ្យពួកគេដេកសន្លប់ដោយស្រវឹងនោះឡើយ ។

### *នៅសម័យដើម មនុស្សបានចៀសវាងការស្រវឹង*

ដោយសារស្រាទំពាំងបាយជូរជារបស់ដែលមានតម្លៃ និងមានអត្ថប្រយោជន៍

ជាច្រើនក្នុងការរស់នៅរបស់មនុស្ស ដូច្នេះ ជាទូទៅពួកគេមិនអាចខ្វះខ្នាយស្រាទំពាំងបាយជូរ ដោយផឹកលេងតាមចិត្តឲ្យស្រវឹងនោះឡើយ ។ មួយវិញទៀត ពួកគេភាគច្រើនបានខ្នះខ្នែងចៀសវាងការស្រវឹងដោយយល់ថា មនុស្សស្រវឹងស្រាចេះតែប្រព្រឹត្តអំពើមិនល្អដល់សង្គម ហើយជាប់មានទោសចំពោះព្រះជាម្ចាស់ផងដែរ ។ តាំងពីមុនសម័យព្រះយេស៊ូវរាប់រយឆ្នាំកន្លងមក ជនជាតិយូដាតែងតែមានច្បាប់ ដែលតំរូវឲ្យពួកគេលាយស្រាទំពាំងបាយជូរ ១ភាគ ជាមួយទឹក ២–៣ភាគ ។[៨] ស្រដៀងគ្នាទៅនឹងការនេះដែរ នៅគ្រានោះ មនុស្សក្នុងចក្រភពក្រិក និងរ៉ូម៉ាំង ជាទូទៅមិនដែលផឹកគ្រឿងស្រវឹងដោយមិនលាយជាមួយនឹងទឹកនោះឡើយ តែពួកគេរមែងលាយស្រា ១ភាគ ជាមួយទឹក ២–៤ភាគ ។[៩] បើលាយស្រាបុរាណជាមួយនឹងទឹកតាមវិធីនេះ វានឹងនៅសល់ជាតិអាល់កុលតិចក្នុងកែវ ហើយមិនបណ្តាលឲ្យស្រវឹងឡើយ លុះត្រាតែផឹកច្រើនលើសលប់ពេក ។ ហេតុនេះហើយបានជា ព្រះគម្ពីរពណ៌នាអំពីជនប្រមឹកថាជា «**ពួកអ្នកដែលអង្គុយផឹកស្រាជាយូរ**» ឬអ្នកដែលផឹកស្រាតាំងពីព្រលឹម រហូតដល់អធ្រាត្រ ។[១០] មនុស្សនៅសម័យនោះយល់ថា ផឹកស្រាលាយ ១ភាគ ជាមួយទឹកគ្រាន់តែ ១ភាគ ប៉ុណ្ណោះ នាំឲ្យទៅជាឆ្កួត ។[១១] ពួកគេក៏យល់ដែរថា អ្នកណាហ៊ានផឹកស្រាដោយមិនលាយជាមួយនឹងទឹក គឺអ្នកនោះផឹកក្នុងគោលបំណងឲ្យស្រវឹងហើយ មនុស្សខ្លះចាត់ទុកជនបែបនោះជា «មនុស្សព្រៃ» ។[១២] ដូច្នេះ យើងឃើញថា

---

(៨) យោងតាមឯកសារ “Wine as a Table-Drink in the Ancient World” ទំព័រ ១៤៨ ។

(៩) យោងតាមសៀវភៅ *Backgrounds of Early Christianity* និពន្ធដោយលោក Everett Ferguson បោះពុម្ពឆ្នាំ ២០០៣ ទំព័រ ១០៦ ។

(១០) ដូចជានៅក្នុងកណ្ឌសុភាសិត ២៣:៣០ និងកណ្ឌអេសាយ ៥:១១ ជាដើម ។

(១១) យោងតាមឯកសារ “Wine as a Table-Drink in the Ancient World” ទំព័រ ១៤៣ ។

(១២) យោងតាមឯកសារ “Wine as a Table-Drink in the Ancient World” ទំព័រ ១៤៥ ។

មនុស្សភាគច្រើននៅសម័យនោះបានចៀសវាងការស្រវឹង ដោយវិធីលាយស្រាជាមួយនឹងទឹក ហើយជាទូទៅមិនបានផឹក ដើម្បីឲ្យស្រវឹងស្រានោះឡើយ ។

*ស្រាទំពាំងបាយជូរ ជានិមិត្តរូបអំពីព្រះពរ និងការជំនុំជំរះរបស់ព្រះជាម្ចាស់*

ខាងលើនេះយើងបានឃើញហើយថា នៅសម័យគម្ពីរ មនុស្សបានប្រើប្រាស់ស្រាទំពាំងបាយជូរ ដើម្បីសំអាតទឹកសម្រាប់ពិសា បំពេញតំរូវការខាងសុខភាពរូបរាងកាយ ឬធ្វើជាថ្នាំព្យាបាលរោគជំងឺ នៅក្នុងគ្រាដែលពុំទាន់មានបច្ចេកទេសអ្វីសម្រាប់ធ្វើទឹកសុទ្ធ ទឹកផ្លែឈើ ឬថ្នាំឱសថនៅឡើយទេ ។ ដូច្នេះ ស្រាទំពាំងបាយជូរបានជួយចិញ្ចឹម ទ្រទ្រង់ និងការពារជីវិតរបស់ពួកគេជារៀងរាល់ថ្ងៃ ។ ហេតុនេះហើយបានជានៅក្នុងព្រះគម្ពីរ ស្រាទំពាំងបាយជូរគឺជានិមិត្តរូបដ៏សំខាន់មួយ អំពីព្រះពរដែលមកពីព្រះជាម្ចាស់ពិតមែន គឺថា នៅពេលដែលព្រះអង្គបានប្រទានស្រូវសាលី និងស្រាទំពាំងបាយជូរ នោះបានសេចក្តីថា ទ្រង់បានប្រទានជីវិត និងសុខភាពល្អដល់ពួកគេតទៅមុខទៀត ។ ស្រាទំពាំងបាយជូរក៏ជានិមិត្តរូបមួយអំពីព្រះពរ ក្នុងសញ្ញាដែលព្រះជាម្ចាស់បានតាំងរវាងព្រះអង្គផ្ទាល់ និងពួកអ៊ីស្រាអែលដែរ ពីព្រោះ បើសិនជាពួកគេបានគោរពប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះអង្គ ដូចជាពួកគេបានព្រមព្រៀងនឹងទ្រង់ហើយ នោះព្រះជាម្ចាស់ក៏បានសន្យាថា នឹងប្រទានឲ្យភោគផលនៅក្នុងស្រុករីកចម្រើនឡើង ជាពិសេស អង្ករសាលី ស្រាទំពាំងបាយជូរ និងប្រេងអូលីវ ដែលជារបស់ពួកគេត្រូវការសម្រាប់ជីវិតប្រចាំថ្ងៃ ។[១៣] ក៏ប៉ុន្តែ បើសិនជាពួកគេមិនបានគោរពប្រតិបត្តិតាមទេ នោះព្រះជាម្ចាស់សន្យាថា ទ្រង់នឹងដាក់បណ្តាសាទៅលើពួកគេវិញ

(១៣) ចោទិយកថា ៧:១២-១៣ និង១១:១៣-១៤ យេរេមា៣ ៣១:១២ យ៉ូអែល ២:១៩-២៤ អេម៉ុស ៩:១៣-១៤ ហាកាយ ១:១១ និងសាការី ៩:១៧ ជាពិសេស ក្នុងព្រះគម្ពីរជាភាសាដើម ។ សូមមើលក្នុង « *ព្រះគម្ពីរជាភាសាខ្មែរបច្ចុប្បន្ន* » “KSV” ផងដែរ ។

ដោយដកអង្គុរសាលី ស្រាទំពាំងបាយជូរ និងប្រេងអូលីវចេញពីស្រុករបស់ពួកគេ ។[១៤]

ជាក់ស្តែងហើយថា ស្រាទំពាំងបាយជូរមិនមែនជានិមិត្តរូបអំពីព្រះពរ មកពីព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សបានស្រវឹងស្រានោះឡើយ ! ផ្ទុយទៅវិញ មានវគ្គគម្ពីរមួយចំនួនធំដែលបង្ហាញថា ក្នុងភាពជាគ្រឿងស្រវឹង ស្រាទំពាំងបាយជូរជានិមិត្តរូបអំពីសេចក្តីក្រេវក្រោធរបស់ព្រះអង្គចំពោះសាសន៍ទាំងឡាយ ដែលថ្វាយបង្គំព្រះក្លែងក្លាយ ។ ក្នុងព្រះគម្ពីរបានចែងទុកថា ពួកគេនឹងធីងធោង ហើយវង្វេងស្មារតីដោយសារការជំនុំជំរះរបស់ព្រះជាម្ចាស់ ដូចជានៅពេលដែលមនុស្សស្រវឹងស្រាដែរ ។[១៥] នៅថ្ងៃចុងក្រោយបង្អស់ ពួកគេនឹងត្រូវបានស្រវឹងដោយ «**ស្រាផងសេចក្តីឃោរឃៅរបស់ព្រះ ជាស្រាឥតលាយ** [*គឺខ្លាំងណាស់ ព្រោះតែពុំបានបន្សាបនឹងទឹក*] **ដែលចាក់ទៅក្នុងពែងនៃសេចក្តីក្រោធរបស់ទ្រង់**» (*វិវរណៈ ១៤:១០*) ។ ទីបំផុតព្រះជាម្ចាស់ ទ្រង់នឹងជាន់ឈ្លីពួកគេ តាមកំហឹងរបស់ព្រះអង្គ ដូចជាមនុស្សបញ្ជាន់ផ្លែទំពាំងបាយជូរក្នុងអាង ពេលគេធ្វើស្រាទំពាំងបាយជូរដែរ ។[១៦]

មួយវិញទៀត រាល់ការប្រព្រឹត្តអំពើអាក្រក់របស់មនុស្ស និងការកើតមានរោគជំងឺ ការញៀន ការរងរបួស និងការស្លាប់ ដែលបណ្តាលមកពីការផឹកស្រវឹងសុទ្ធតែជាទណ្ឌកម្មក្នុងជីវិតឥឡូវនេះ ដែលព្រះជាម្ចាស់ដាក់មកលើមនុស្សមានបាបមិនមែនជាព្រះពររបស់ព្រះអង្គនោះឡើយ ។

---

(១៤) ចោទិយកថា ២៨:៣៩ យេរេមា ៤៨:៣៣ បរិទេវ ២:១២ ហូសេ ២:៩ យ៉ូអែល ១:១០ និងហាកាយ ២:១៦ ។

(១៥) ទំនុកតម្កើង ៦០:៣ និង៧៥:៧-៨ អេសាយ ៥១:១៧-២៣ យេរេមា ២៥:១៥-១៦ និង ៤៨:២១-២៦ ហើយនិងហាបាគុក ២:១៦ ។

(១៦) អេសាយ ៦៣:៣ យ៉ូអែល ៣:១៣ ហើយនិងវិវរណៈ ១៤:១៧-២០ និង១៩:១៣-១៥ ។

# *ជំពូក ទី៤*
# *ស្រានៅសម័យបច្ចុប្បន្ន*

## *របៀបធ្វើស្រានៅសម័យបច្ចុប្បន្ន*

ក្នុងរយៈពេលរាប់រយឆ្នាំចុងក្រោយនេះមក ជាទូទៅមនុស្សលែងចាត់ទុកការស្រវឹងជាអំពើអបាយមុខដ៏ធំទៀតហើយ ទោះបីជាមនុស្សខ្លះនៅតែគិតថា វាជាការមិនល្អក៏ដោយ ។ ដូច្នេះ ទើបគេបានអភិវឌ្ឍន៍របៀបធ្វើ និងបច្ចេកទេសជាច្រើនណាស់សម្រាប់ការបង្កើនជាតិអាល់កុលក្នុងគ្រឿងស្រវឹង ដើម្បីធ្វើឲ្យមនុស្សកាន់តែទទួលអារម្មណ៍សប្បាយរីករាយ ព្រមទាំងឲ្យបានឆាប់ស្រវឹងស្រាជាងធម្មតាផង ។ សូមមើលឧទាហរណ៍ខ្លះអំពីរបៀបធ្វើស្រា និងបច្ចេកទេសសម្រាប់ការបង្កើនជាតិអាល់កុលដូចខាងក្រោមនេះជាដើម ៖

- គេបានច្នៃដើមទំពាំងបាយជូរដោយរើសពូជ ធ្វើឲ្យបង្កើតផ្លែមានជាតិស្ករលើសជាងធម្មតា ដើម្បីបង្កើនជាតិអាល់កុលក្នុងស្រា ពីព្រោះ នៅពេលដែលគេយកផ្លែទំពាំងបាយជូរទៅធ្វើស្រា ជាតិស្ករក្នុងវានឹងក្លាយទៅជាជាតិអាល់កុលវិញ ។ ជួនកាល គេបន្ថែមស្ករក្នុងគ្រឿងផ្សំ ដើម្បីបង្កើនជាតិអាល់កុលតែម្តង ។

- គេបិតស្រាដោយប្រើប្រាស់ម៉ាស៊ីន ដែលមានបច្ចេកទេសខាងគីមីវិទ្យា ដើម្បីបន្ថែមកំដៅ និងសំពាធ ប្រយោជន៍នឹងបង្កើនជាតិអាល់កុលក្នុងស្រា ឲ្យមានច្រើនជាងស្រាធម្មជាតិ ហើយផលិតវាបានយ៉ាងឆាប់រហ័សជាងធម្មតាទៀតផង ។

- ក្នុងស្រាប្រភេទខ្លះ គេបានផ្ទុកទឹកអាល់កុល “ethanol” បន្ថែមតែម្តង ។

- គេបង្កើនជាតិហ្គាស់ក្នុងស្រា ដោយបច្ចេកទេសទំនើប ពីព្រោះជាតិហ្គាស់ធ្វើឲ្យ

ជាតិអាល់កុលជ្រាបចូលទៅក្នុងចរន្តឈាមបានយ៉ាងលឿនជាងធម្មតា លទ្ធផលគឺធ្វើឲ្យមនុស្សឆាប់បានពុលស្រាជាងមុន ។

- គេធ្វើស្រាក្នុងរោងចក្រធំៗ ដែលផលិតវាយ៉ាងឆាប់រហ័ស ជាច្រើនក្រៃលែង ដើម្បីឲ្យស្រាមានតម្លៃទាបនៅក្នុងទីផ្សារ ប្រយោជន៍ឲ្យគ្រប់ៗគ្នាមានលទ្ធភាពទិញតាមចិត្តគេចង់បាន ។ ធ្វើដូច្នេះ ក្រុមហ៊ុន និងអ្នកលក់ស្រាបានចំណេញជាច្រើនជាង ដោយដាក់លក់ច្រើនណាស់ លើគំនរទុក្ខសោកអ្នកដទៃ ។

សេចក្ដីទាំងនេះបង្ហាញឲ្យឃើញច្បាស់លាស់ថា គ្រឿងស្រវឹងដែលគេផលិតសព្វថ្ងៃនេះ គឺជាប្រភេទឧស្សាហកម្មនៅក្នុងរោងចក្រ ដោយប្រើបច្ចេកទេសទំនើបៗ វាមិនដូចស្រាទំពាំងបាយជូរពីបុរាណ ដែលគេធ្វើដោយរបៀបធម្មជាតិជាប្រភេទកសិកម្មនៅសម័យគម្ពីរនោះឡើយ ។

## *ការប្រើប្រាស់ស្រានៅសម័យបច្ចុប្បន្ន*

មិនដូចសម័យគម្ពីរ នៅសម័យបច្ចុប្បន្នកាលនេះ មិនចាំបាច់ប្រើប្រាស់ស្រាដើម្បីធ្វើអ្វីទាំងអស់ ដោយឥឡូវនេះ យើងមានបច្ចេកទេសជាច្រើនណាស់សម្រាប់ច្រោះទឹកស្អាត រំងាប់មេរោគ បង្ខាំងដំណើរឡើងជូរក្នុងទឹកផ្លែឈើ និងរក្សាទុកផលិតផលបានយូរ ដោយមិនឲ្យឡើងជូរបាន ។ យើងក៏មានភេសជ្ជៈច្រើនណាស់សម្រាប់ជួយទ្រទ្រង់ដល់សុខភាព ដែលមនុស្សនៅសម័យបុរាណពុំមានទេ ដូចជាទឹកសុទ្ធ ទឹកផ្លែឈើ និងទឹកក្រូច ។ល។ ភេសជ្ជៈបែបនេះមិនមានជាតិអាល់កុលទេ តែវាមានរសជាតិគ្រប់បែបយ៉ាង ហើយឆ្ងាញ់ពិសាទៀតផង ។ យើងថែមទាំងមានបច្ចេកទេសខាងវិជ្ជាពេទ្យល្មមនឹងអាចផលិតថ្នាំឱសថគ្រប់មុខបាន ដែលព្យាបាលឲ្យចំរោគជំងឺគ្រប់ប្រភេទ ដោយមិនបណ្ដាលឲ្យទៅជាស្រវឹង ។ ដូច្នេះ មិនដូចជាមនុស្ស

នៅសម័យបុរាណ ពួកយើងលែងត្រូវការប្រើប្រាស់ស្រាទៀតហើយ ។

ក៏ប៉ុន្តែ ឥឡូវនេះមនុស្សផឹកស្រាដោយមានបំណងចិត្តតែមួយគត់ គឺដើម្បីសប្បាយ ហើយ បើសិនជាផឹកឲ្យស្រវឹង គ្មាននរណាម្នាក់មើលងាយទេ ពីព្រោះគេលែងចាត់ទុកការស្រវឹងជាអំពើអបាយមុខទៀតហើយ ។ មិនដូចជាស្រាទំពាំងបាយជូរបុរាណ ដែលគេត្រូវផឹកច្រើន និងចំណាយពេលយូរទើបបានស្រវឹង បើសិនជាផឹកស្រាសម័យនេះគ្រាន់តែពីរ ឬបីកែវប៉ុណ្ណោះ នោះនឹងត្រូវស្រវឹងហើយ ។ បើយើងស្វែងរកអ្នកណាម្នាក់ ដែលផឹកដោយខំប្រឹងចៀសវាងស្រវឹងដូចមនុស្សនៅសម័យបុរាណ គឺនៅសល់តិចណាស់ ពីព្រោះ មនុស្សភាគច្រើនផឹកដើម្បីឲ្យបានស្រវឹងនោះឯង ។ ហេតុនេះហើយបានជា មនុស្សនៅសម័យនេះ ពួកគេមិនដែលបន្សាបជាតិអាល់កុលដោយលាយស្រាជាមួយនឹងទឹក ដូចមនុស្សនៅសម័យគម្ពីរនោះឡើយ ។

## *ជំពូក ទី៥*
## *តើព្រះគម្ពីរគាំទ្រឲ្យយើងផឹកគ្រឿងស្រវឹង សម័យបច្ចុប្បន្ននេះពិតមែនឬទេ ?*

យើងបានឃើញរួចហើយថា នៅសម័យគម្ពីរ ពួកគេបានធ្វើស្រាទំពាំងបាយជូរជាប្រភេទកសិកម្ម ដោយប្រើវិធីសាស្ត្រធម្មជាតិ ។ ស្រាដែលគេបានធ្វើនោះមិនមានជាតិអាល់កុលខ្លាំងដល់កំរិតស្រាសម័យបច្ចុប្បន្នទេ ពីព្រោះ ពុំទាន់មានបច្ចេកទេសទំនើបៗសម្រាប់បង្កើនជាតិអាល់កុលដូចមាននៅសព្វថ្ងៃនេះនៅឡើយ ។ ពួកគេបានធ្វើស្រាទំពាំងបាយជូរដោយគោលបំណងរក្សាទុកភោគផលក្នុងស្រុក ហើយសម្រាប់ជាគ្រឿងមួយ ដែលមានប្រយោជន៍ជាច្រើនដល់ជីវិតរស់នៅរបស់មនុស្ស ពីព្រោះគេបានប្រើប្រាស់វាជាថ្នាំដើម្បីសំអាតទឹកពិសា ជាភេសជ្ជៈផ្តល់ជីវជាតិចិញ្ចឹមរូបរាងកាយហើយជាថាំឱសថព្យាបាលរោគជំងឺផងដែរ ។ ដូច្នេះ គ្រប់គ្នាបានប្រើប្រាស់ស្រាទំពាំងបាយជូរ ដើម្បីទ្រទ្រង់ និងការពារសុខភាពរបស់ពួកគេជាប្រចាំថ្ងៃ ។ ដោយមូលហេតុទាំងអស់នេះហើយបានជា ក្នុងព្រះគម្ពីរ ស្រាទំពាំងបាយជូរបានក្លាយជានិមិត្តរូបមួយអំពីព្រះពរ ដែលព្រះជាម្ចាស់ប្រទានមកពួកគេ ។ ប៉ុន្តែ រួមជាមួយនឹងនេះ ពួកគេក៏បានយល់ដែរថា ការផឹកស្រវឹងជាអំពើអបាយមុខ ដែលបង្កើតបានជាផលមិនល្អដល់សង្គម ហើយពួកគេថែមទាំងរាប់អស់អ្នកណាដែលផឹកស្រាខ្លាំង ឬមនុស្សប្រមឹកជាជនថោកទាបទៀតផង ។ ក្នុងភាពជាគ្រឿងស្រវឹង ស្រាទំពាំងបាយជូរជានិមិត្តរូបអំពីការជំនុំជំរះរបស់ព្រះជាម្ចាស់ ។ ពួកគេភាគច្រើនក៏បានខ្នះខ្នែងចៀសវាងការស្រវឹងដោយប្រើវិធីលាយស្រាទំពាំងបាយជូរជាមួយនឹងទឹកជានិច្ច ហើយ តាមការប្រើប្រាស់ជាធម្មតា វាមិនបាននាំឲ្យស្រវឹងទេ ។ ដូច្នេះ ព្រះជាម្ចាស់បានអនុញ្ញាតឲ្យពួកគេ

ប្រើប្រាស់ស្រាទំពាំងបាយជូរ ដោយគ្រាន់តែហាមប្រាមកុំឲ្យស្រវឹងបានហើយ ។

ផ្ទុយទៅវិញ នៅក្នុងសម័យបច្ចុប្បន្ន ជាទូទៅមនុស្សលែងចាត់ទុកការស្រវឹងជាអំពើអបាយមុខទៀតហើយ ។ ហើយ ថ្វីដ្បិតតែយើងលែងត្រូវការស្រាសម្រាប់ធ្វើអ្វីៗ ដែលមានប្រយោជន៍ក្នុងជីវិតរស់នៅរបស់ពួកយើងរួចហើយក៏ដោយ ក៏មនុស្សនៅតែចូលចិត្តផឹកស្រាដើម្បីសប្បាយ ហើយ មនុស្សភាគច្រើនថែមទាំងនិយមផឹកដល់ស្រវឹងទៀតផង ។ ហេតុនេះហើយបានជា គេខ្នះខ្នែងអភិវឌ្ឍន៍របៀបផលិតជាច្រើនដែលអាចកើនជាតិអាល់កុលក្នុងស្រា ដើម្បីឲ្យមនុស្សឆាប់បានពុលជាតិអាល់កុលជាងមុន ។ មិនដូចសម័យមុនៗទេ សព្វថ្ងៃនេះ គេផលិតស្រាជាប្រភេទឧស្សាហកម្មតាមរោងចក្រ ដោយប្រើបច្ចេកទេសទំនើបៗ ឲ្យវាមានជាតិអាល់កុលកាន់តែខ្លាំង ហើយឲ្យដាក់លក់កាន់តែច្រើនផងដែរ ។ ដោយព្រោះតែមនុស្សនៅសម័យបច្ចុប្បន្នមានគោលបំណងធំមួយក្នុងការផឹកស្រា គឺដើម្បីឲ្យស្រវឹង ដូច្នេះហើយ ពួកគេមិនដែលបន្សាបស្រានឹងទឹកដូចនៅសម័យបុរាណនោះឡើយ ។

| ស្រាបុរាណនៅសម័យគម្ពីរ | ស្រានៅសម័យបច្ចុប្បន្នកាលនេះ |
|---|---|
| ▪ ផលិតជាប្រភេទកសិកម្ម ដោយគ្មានបច្ចេកទេសទំនើបសម្រាប់បង្កើនជាតិអាល់កុលទេ | ▪ ផលិតជាប្រភេទឧស្សាហកម្ម ដោយអភិវឌ្ឍន៍បច្ចេកទេសច្រើនសម្រាប់បង្កើនជាតិអាល់កុល |
| ▪ គោលបំណងធំគឺ ធ្វើស្រា ដើម្បីរក្សាទុកផលិតផលឲ្យបានយូរ | ▪ គោលបំណងធំគឺ ធ្វើស្រា ដើម្បីមានគ្រឿងស្រវឹងតែប៉ុណ្ណោះ |
| ▪ ប្រើប្រាស់ជាថ្នាំសម្រាប់សំអាតទឹក ជាភេសជ្ជៈផ្តល់ជីវជាតិ និងជាថ្នាំឱសថ | ▪ ប្រើប្រាស់ជាគ្រឿងស្រវឹងតែមួយមុខគត់ |
| ▪ ប្រើប្រាស់ជាប្រចាំថ្ងៃ ដោយវិធីលាយស្រាជាមួយនឹងទឹកជានិច្ច | ▪ ផឹកដើម្បីសប្បាយ ដោយពុំដែលលាយជាមួយនឹងទឹកទេ |
| ▪ តាមការប្រើប្រាស់ធម្មតា ពុំបណ្តាលឲ្យស្រវឹងទេ | ▪ តាមការប្រើប្រាស់ធម្មតា បណ្តាលឲ្យស្រវឹង |

### *គ្រីស្ទបរិស័ទមិនត្រូវផឹកគ្រឿងស្រវឹងសម័យបច្ចុប្បន្នឡើយ*

ដូចបានបរិយាយរួចមកហើយ គ្រីស្ទបរិស័ទដែលចង់ផឹកស្រា ពួកគេសំអាងទៅលើភស្តុតាងក្នុងព្រះគម្ពីរដែលបង្ហាញថា មនុស្ស រួមទាំងព្រះយេស៊ូវ និងពួកសិស្សរបស់ព្រះអង្គ បានផឹកស្រាទំពាំងបាយជូរ ដូច្នេះ គេគិតថា យើងក៏អាចផឹកស្រាធ្វើនៅសម័យបច្ចុប្បន្នដូចគ្នាដែរ ។ គេក៏និយាយដែរថា ព្រះគម្ពីរមិនបានហាមការផឹកស្រាជាដាច់ខាតទេ ។ ក៏ប៉ុន្តែ ការសំអាងបែបនេះមិនត្រឹមត្រូវឡើយ ពីព្រោះ ស្រាបុរាណ និងស្រាដែលគេធ្វើសព្វថ្ងៃនេះ ព្រមទាំងគោលបំណងរបស់មនុស្សក្នុងការប្រើប្រាស់ស្រារវាងសម័យគម្ពីរ និងសម័យបច្ចុប្បន្ន គឺមិនដូចគ្នាទេ ។ ជាក់ស្តែងហើយថា ស្រាទំពាំងបាយជូរបុរាណ ដែលបានលាយជាមួយនឹងទឹកក្នុងពែងរបស់ព្រះយេស៊ូវនោះ វាមិនដូចស្រាក្នុងដប ឬកំប៉ុងដែលគេលក់នៅបច្ចុប្បន្ននេះឡើយ ។ ដោយព្រោះស្រាទំពាំងបាយជូរបុរាណមានការប្រើប្រាស់ និងមានប្រយោជន៍ជាច្រើន ហើយមនុស្សនៅសម័យដើមបានចៀសវាងការស្រវឹង ទើបព្រះគម្ពីរអាចអនុញ្ញាតឲ្យពួកគេប្រើប្រាស់វាបាន ។ ក៏ប៉ុន្តែ នៅសម័យបច្ចុប្បន្នកាលនេះ គ្រឿងស្រវឹងបានផលិតដើម្បីតែប្រើប្រាស់សម្រាប់ការជប់លៀង ឬការផឹកលេងឲ្យសប្បាយប៉ុណ្ណោះ ហើយវារមែងនាំឲ្យស្រវឹង ។ ដូច្នេះ យើងយកសេចក្តីខាងលើនេះ ដែលមើលឃើញក្នុងព្រះគម្ពីរចំពោះស្រាទំពាំងបាយជូរបុរាណ ក្នុងវប្បធម៌បុរាណ មកអនុវត្តចំពោះគ្រឿងស្រវឹងនៅសម័យឥឡូវក្នុងវប្បធម៌របស់ពួកយើង គឺខុសទាំងស្រុង ។ សេចក្តីក្នុងព្រះគម្ពីរ ដែលយើងត្រូវតែអនុវត្តចំពោះគ្រឿងស្រវឹងនៅសម័យនេះ គឺមានដូចតទៅ ៖

- គ្មានការសង្ស័យអ្វីថា ក្នុងព្រះបន្ទូលរបស់ព្រះអង្គ ព្រះជាម្ចាស់បានហាមប្រាមការស្រវឹងជាដាច់ខាត ដូច្នេះ ការប្រើប្រាស់គ្រឿងណាមួយ ដែលបានធ្វើដោយគោលបំណងជួយឲ្យគេឆាប់បានស្រវឹង គឺជាអំពើជំទាស់ទៅនឹងការបង្រៀនជាក់ស្តែងក្នុងព្រះគម្ពីរតែម្តង ។

- នៅក្នុងរូបភាពជាគ្រឿងស្រវឹង ស្រាទំពាំងបាយជូរនៅក្នុងព្រះគម្ពីរគឺជានិមិត្តរូបអំពីព្រះហឫទ័យក្រេវក្រោធ និងការជំនុំជំរះរបស់ព្រះជាម្ចាស់ចំពោះមនុស្សមានបាបដែលបានបះបោរ ។ នៅសម័យឥឡូវនេះ វាមិនខុសគ្នាទេ ហើយព្រះជាម្ចាស់មិនបានប្ដូរព្រះហឫទ័យរបស់ព្រះអង្គចំពោះការស្រវឹងនោះឡើយ ជាពិសេស នៅពេលដែលគេធ្វើស្រាឲ្យកាន់តែខ្លាំង ដើម្បីឲ្យមនុស្សរឹតតែឆាប់ស្រវឹងជាងមុន ។

ព្រះគម្ពីរមិនដែលគាំទ្រគ្រឿងណាមួយ ដែលគេផលិតដោយគោលបំណងធ្វើឲ្យមនុស្សស្រវឹងនោះឡើយ ។ ដូច្នេះ អស់អ្នកណាដែលផឹកស្រាដ៏ខ្លាំងរបស់សម័យនេះ ដើម្បីសប្បាយ អ្នកនោះគាំទ្រដោយសារតែខ្លួនឯងប៉ុណ្ណោះ ហើយបានណែនាំឲ្យធ្វើដូច្នេះ ដោយសារលោកីយ៍ និងចិត្តលោភលន់របស់ខ្លួន មិនមែនព្រះវិញ្ញាណបរិសុទ្ធនោះឡើយ ។ សូម្បីតែសាសន៍ដទៃនៅសម័យគម្ពីរ ដែលសុទ្ធតែជាអ្នកមិនជឿលើព្រះជាម្ចាស់ ក៏មិនគាំទ្រដែរ ពីព្រោះ ពួកគេភាគច្រើនមិនព្រមផឹកស្រាខ្លាំងដល់កំរិតស្រាសម័យនេះទេ ។[១៧] នៅសម័យបច្ចុប្បន្ននេះ គឺជាគ្រាមួយដែលមនុស្សលែងត្រូវការប្រើប្រាស់ស្រានៅគ្រប់វិស័យទាំងអស់ទៀតហើយ យើងគ្មានមូលហេតុត្រឹមត្រូវល្អក្នុងការផឹកភេសជ្ជៈណាមួយ ដែលលោកីយ៍ធ្វើ ដើម្បីឲ្យស្រវឹងខុសពីព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះឡើយ ។

ប្រសិនបើស្រាទំពាំងបាយជូរ ដែលគេបានធ្វើតាមធម្មជាតិ ហើយបន្សាបនឹងទឹកក្នុងសម័យគម្ពីរអាចជា «**របស់បញ្ឆោតមើលងាយ និងបង្កើតការឡូឡា**» យ៉ាងហ្នឹងទៅហើយ ចុះទំរាំបើស្រា ដែលគេបង្កើនជាតិអាល់កុលដោយបច្ចេកទេសទំនើបវិញ តើវានឹងរឹតតែជា «**របស់បញ្ឆោតមើលងាយ និងបង្កើតការឡូឡា**» លើសនេះយ៉ាងណាទៅទៀត ? ប្រសិនបើអ្នកវង្វេងទៅដោយគ្រឿងស្រវឹងក្នុងសម័យគម្ពីរ នោះ «**ឈ្មោះថា**

(១៧) យោងតាមសៀវភៅ *Christians and Alcohol* ទំព័រ ៨៤ ។

**គ្មានប្រាជ្ញា**» យ៉ាងហ្នឹងទៅហើយ ចុះទំរាំបើអ្នកវង្វេងទៅដោយគ្រឿងស្រវឹងសម័យនេះ ដែលរឹតតែខ្លាំង ហើយមិនដែលបន្សាបនឹងទឹកវិញ តើគេនឹងរឹងរឹតតែខ្វះប្រាជ្ញាយ៉ាងណាទៅទៀត ? ក្រុមហ៊ុនបានបង្កើនជាតិអាល់កុលក្នុងស្រាកាន់តែច្រើន ហើយហាងលក់ភេសជ្ជៈបានចំណេញដោយលក់វាក្នុងភូមិកាន់តែច្រើនយ៉ាងណា សង្គមយើងក៏ត្រូវទទួលរងនូវឥទ្ធិពលដ៏អាក្រក់របស់វាកាន់តែច្រើនយ៉ាងនោះដែរ ! ដូចជាការលេងល្បែង ខ្ជិលធ្វើការងារ ការខាតបង់ថវិកា ភាពក្រីក្រ ការផិតក្បត់គ្នា ការលែងលះគ្នា អំពើហិង្សា ឃាតកម្ម ពេស្យាចារ ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ ពុករលួយ ការបង្វែរយុត្តិធម៌ និងការបំពានទៅលើសិទ្ធិមនុស្ស ។ល។ អស់អ្នកណាដែលមើលបំណាំ ធ្វើមិនដឹង មិនឮអំពីការបំផ្លិចបំផ្លាញនូវសីលធម៌ គុណធម៌ និងវប្បធម៌ក្នុងសង្គមរបស់ខ្លួន ដោយការផឹកគ្រឿងស្រវឹងឲ្យតែសប្បាយខ្លួនឯង អ្នកនោះពិតជាគ្មានប្រាជ្ញាសោះឡើយ ។

មួយវិញទៀត ក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ពួកគេ ក្រុមហ៊ុនស្រាតែងតែសន្យាថា ពួកយើងនឹងទទួលបានរង្វាន់ធំៗ ក្លាយជាអ្នកមាន ឬមានសុភមង្គលក្នុងជីវិតរបស់ពួកយើងជានិច្ច ។ តែរង្វាន់ពិត ដែលស្រារមែងតែងតែផ្តល់មកពួកយើងគឺជាភាពក្រីក្រ អំពើហិង្សា និងសេចក្តីវេទនាទៅវិញ ។ វាអាក្រក់ជាងនេះទៅទៀត ក្នុងអំឡុងពេលនោះឯង គឺពួកក្រុមហ៊ុនទេតើ ដែលបានក្លាយទៅជាអ្នកមាន ហើយមានសុភមង្គល ដោយបានយកផលចំណេញមកពីកាបូបលុយរបស់មនុស្ស ដែលត្រូវគេបញ្ឆោត តាមរយៈការផ្សព្វផ្សាយពាណិជ្ជកម្មទាំងនោះ ។

គួរឲ្យសោកស្តាយបំផុត អ្នកណាដែលផឹកគ្រឿងស្រវឹងគឺគាំទ្រលទ្ធផលដ៏អាក្រក់ទាំងនេះក្នុងសង្គមរបស់ខ្លួន រួមទាំងមានមនុស្សខ្លះដែលអះអាងថា គេជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទទៀតផង ។ គ្រីស្ទបរិស័ទ ដែលព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យធ្វើជាអំបិល និងជាពន្លឺទៅដល់មនុស្សលោក តើពួកគេអាចរួមចំណែកជាមួយនឹង

ពួកអ្នកដែលមិនជឿ ក្នុងការបង្ខូចដល់សង្គមរបស់ខ្លួនទៅវិញ ដោយផឹកគ្រឿងស្រវឹង យ៉ាងដូចម្ដេចកើត ? មិនមែនព្រះអម្ចាស់ទេ ដែលបានធ្វើគ្រឿងស្រវឹងដ៏ខ្លាំងនេះ ក្លាយទៅជារបស់សំខាន់ក្នុងវប្បធម៌នៃមនុស្សមិនបរិសុទ្ធដូច្នេះ ។ គឺជាលោកីយ៍ឯណោះ ដែលបានធ្វើអញ្ចឹង ហើយ ឥទ្ធិពលរបស់គ្រឿងស្រវឹងនេះឯង គឺវានឹងនាំមនុស្សឲ្យប្រព្រឹត្តអំពើបាបជំទាស់ទៅនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់កាន់តែខ្លាំងឡើងៗ តាមចិត្តលោភលន់របស់ពួកគេ ។

*មូលហេតុពិតដែលមនុស្សខ្លះនៅតែចង់ផឹកស្រា*

ខាងលើនេះ យើងបានឃើញលទ្ធផលដ៏អាក្រក់ដល់សង្គមនៃការផឹកស្រា ហើយនិងការខ្វះប្រាជ្ញារបស់អ្នកដែលផឹកស្រាដើម្បីសប្បាយខ្លួនឯង នៅលើគំនរទុក្ខសោករបស់គ្រួសារ និងអ្នកភូមិឯទៀតៗរបស់ពួកគេ ។ យើងក៏បានឃើញហើយដែរថា មនុស្សនៅសម័យគម្ពីរមានហេតុផលល្អជាច្រើន ក្នុងការប្រើប្រាស់ស្រាទំពាំងបាយជូរ ហើយ ពួកគេភាគច្រើនរមែងតែចៀសវាងការស្រវឹង ។ ផ្ទុយទៅវិញ នៅសម័យឥឡូវនេះ យើងមិនត្រូវការស្រាសម្រាប់ធ្វើអ្វីណាមួយដែលល្អ ឬអាចយកជាការបានទេ ក្រៅពីការផឹកលេងសប្បាយមួយមុខគត់ ទាំងត្រូវទទួលយកលទ្ធផលដ៏អាក្រក់របស់វាមកដាក់ក្នុងសង្គម ។ មួយវិញទៀត អ្នកណាដែលផឹកគ្រឿងណាមួយ ដែលផលិតក្នុងគោលបំណងធ្វើឲ្យមនុស្សស្រវឹង អ្នកនោះបានប្រព្រឹត្តការជំទាស់ទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយ ។ ដូច្នេះ តើដោយមូលហេតុអ្វីបានជាមនុស្ស រួមទាំងគ្រីស្ទបរិស័ទខ្លះ នៅតែចង់ផឹកស្រានាសម័យឥឡូវនេះ ? បើយើងស្វែងរកអ្នកណាដែលផឹកស្រាក្នុងគោលបំណងចង់គាប់ដល់ព្រះហឫទ័យព្រះជាម្ចាស់ នោះពុំមានសល់សូម្បីតែម្នាក់ ។ ក៏ប៉ុន្តែ មានហេតុផលមិនត្រឹមត្រូវជាច្រើនសម្រាប់ការផឹកស្រា ដែលគេមិនហ៊ាននិយាយ ដូចខាងក្រោមនេះជាដើម ៖

- តាមការពិត មនុស្សខ្លះចូលចិត្តអារម្មណ៍ស្រៀងៗ ធីងធោង ឬរំភើបរីករាយដែលបណ្ដាលមកពីការពុលជាតិអាល់កុល ឬអាក្រក់ជាងនេះទៅទៀត គេជាប់ញៀនស្រាតែម្ដង ។
- មនុស្សខ្លះផឹកដើម្បីបំភ្លេចរឿងរ៉ាវ និងបញ្ហាដែលកើតមាននៅក្នុងជីវិត ។ ក៏ប៉ុន្តែស្រវឹងហើយ លទ្ធផលចុងក្រោយគឺ ចេះតែបង្ករឿង និងបញ្ហារឹតតែច្រើនឡើង និងអាក្រក់ជាងមុនទៅទៀត ដូច្នេះ គេរឹតតែចង់ផឹក !
- មនុស្សខ្លះមិនចេះទ្រទ្រាំការបៀតបៀន ឬការបង្ខិតបង្ខំឲ្យផឹកស្រានោះទេ តែគេចង់ទុកមុខឲ្យខ្លួនសិនដោយមានអំនួត កុំឲ្យខ្មាសគេ ឬមួយ គេរាប់អាន និងកោតខ្លាចដល់មនុស្សមានបាបជាជាងព្រះអម្ចាស់ ដោយយកពាក្យថា «កុំឲ្យបាត់មិត្ត» ជាលេស ។
- មនុស្សខ្លះផឹកសប្បាយដើម្បីកំសាន្តចិត្ត ហើយលទ្ធផលគឺ គេបណ្ដោយខ្លួនឲ្យប្រព្រឹត្តអំពើអាក្រក់យ៉ាងច្រើនហួរហៀរ ទៅតាមការលោភលន់ខាងនិស្ស័យសាច់ឈាម ដែលទប់ទល់លែងបាន ។
- មនុស្សខ្លះគ្មានប្រាជ្ញា ហើយ យើងខំប្រឹងដាស់តឿនគេឲ្យប្រព្រឹត្តអំពើត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏គេចេះតែចាញ់ការល្បួងដែរ ។

អស់ទាំងមូលហេតុដូចជាខាងលើនេះ តើវាមិនមែនប្រឆាំងជំទាស់ទៅនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ប្រជារាស្ត្រដ៏បរិសុទ្ធរបស់ព្រះអង្គដែរឬទេ ? យើងឃើញហើយថា ព្រះជាម្ចាស់ ទ្រង់ស្អប់ការស្រវឹងណាស់ ហើយព្រះអង្គមានព្រះបន្ទូលប្រាប់យើងយ៉ាងច្បាស់លាស់ក្នុងព្រះគម្ពីររួចជាស្រេចហើយ ។ ដូច្នេះ អ្នកណាដែលផឹកស្រាបច្ចុប្បន្ន ដែលរមែងបណ្ដាលឲ្យស្រវឹង ដោយមូលហេតុបែបនេះ

គេមិនអាចគាប់ទៅដល់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ ។ ផ្ទុយទៅវិញ គេផឹកដោយគោលបំណងគាប់ចិត្តដល់មនុស្សមានបាប និងស្តាប់តាមគេដើម្បីយកសប្បាយជាជាងប្តេជ្ញាចិត្តបម្រើ គោរពប្រតិបត្តិ និងគាប់ទៅដល់ព្រះហឫទ័យព្រះជាម្ចាស់ ។

*ហេតុអ្វីបានជាព្រះអម្ចាស់មិនហាមការផឹកគ្រឿងស្រវឹងគ្រប់ប្រភេទក្នុងព្រះគម្ពីរតែម្តង ?*

បើយោងតាមអស់ទាំងសេចក្តីក្នុងជំពូក ទី៣ អំពីការប្រើប្រាស់ស្រាទំពាំងបាយជូរនៅសម័យគម្ពីរ ចំពោះសំណួរនេះ យើងរកឃើញចម្លើយបីដូចតទៅ ៖ (១) នៅសម័យគម្ពីរ ពុំមានបច្ចេកទេសទំនើបសម្រាប់ច្រោះទឹកស្អាត រក្សាទុកទឹកផ្លែឈើឲ្យបានយូរ ឬធ្វើថ្នាំឱសថទេ ដូច្នេះហើយ ការប្រើប្រាស់ស្រាទំពាំងបាយជូរគឺជាការចាំបាច់ក្នុងការរស់នៅជាប្រចាំថ្ងៃរបស់ពួកគេ ។ (២) នៅសម័យគម្ពីរ ក្នុងទំលាប់ប្រើប្រាស់ស្រាទំពាំងបាយជូរជាទូទៅ វាជាគ្រឿងផ្សំ ដែលលាយជាមួយនឹងទឹកហើយ មិនបណ្តាលឲ្យមនុស្សទៅជាស្រវឹងទេ ។ (៣) ក្នុងសង្គមមនុស្សនៅសម័យគម្ពីរមានច្បាប់គ្រប់គ្រាន់ហើយ ដែលហាមប្រាមការស្រវឹង ។ ជាទូទៅ ពួកគេមិនផឹកស្រាទំពាំងបាយជូរដើម្បីស្រវឹងនោះឡើយ ដោយយល់ថា ការស្រវឹងជាអំពើអបាយមុខដ៏ធំ ដែលរមែងតែងតែមានលទ្ធផលដ៏អាក្រក់មកតាមក្រោយ ។ ដូច្នេះ ហាមកុំឲ្យមនុស្សនៅសម័យគម្ពីរផឹកស្រាទំពាំងបាយជូរជាដាច់ខាតធ្វើអ្វីទៀត ? មិនមែនពួកគេត្រូវការបញ្ញត្តហាមប្រាមការផឹកស្រាដូច្នេះឡើយ គឺជំនាន់ពួកយើងទេតើ ដែលរីករាយផឹកស្រាដល់ស្រវឹង ហើយចេះតែប្រព្រឹត្តអំពើខិលខូច ល្មមនឹងត្រូវការបញ្ញត្តហាមប្រាមការផឹកស្រាគ្រប់ប្រភេទយ៉ាងដូច្នេះ ។

ក៏ប៉ុន្តែ ថ្វីបើជាព្រះអម្ចាស់បានដាក់ច្បាប់ហាមប្រាមការផឹកគ្រឿងស្រវឹងគ្រប់ប្រភេទក៏ដោយ ក៏វានៅតែគ្មានប្រយោជន៍ដល់សង្គមមនុស្សដដែល ពីព្រោះ «**ក្រឹត្យវិន័យគ្រាន់តែសំដែងឲ្យស្គាល់អំពើបាបប៉ុណ្ណោះ**» (*រ៉ូម ៣:២០*) តែវាគ្មានសមត្ថភាព

អាចនឹងជួយបង្ខាំងនិស្ស័យសាច់ឈាមរបស់មនុស្ស ដែលរមែងតែងតែប្រព្រឹត្តអំពើបាបនោះបានសោះឡើយ (*រ៉ូម ៨:៣ និង៧-៨*) ។ ដូចគ្នានេះដែរ សីល ទី៥ ក្នុងពុទ្ធសាសនាហាមប្រាមការផឹកគ្រឿងស្រវឹងគ្រប់ប្រភេទរួចជាស្រេចទៅហើយ តែយើងឃើញលទ្ធផលជាក់ស្តែងក្នុងសង្គមខ្មែរ គឺថា មនុស្សភាគច្រើននៅតែផឹកដដែលហើយជាធម្មតា ដល់ស្រវឹងថែមទៀតផង ។

សំខាន់ជាងនេះទៅទៀត ព្រះអម្ចាស់ ទ្រង់សព្វព្រះហឫទ័យឲ្យអស់អ្នកណាដែលបានទទួលសេចក្តីសង្គ្រោះរួចហើយ សម្រេចតាមសេចក្តីសុចរិត ដែលក្រឹត្យវិន័យបង្គាប់មក ដោយការប្រព្រឹត្តតាមព្រះវិញ្ញាណបរិសុទ្ធទ្រង់ណែនាំ (*រ៉ូម ៨:៤*) ។ អ្នកណាមានព្រះវិញ្ញាណស្ថិតនៅក្នុងខ្លួន ហើយចេះប្រព្រឹត្តតាមព្រះអង្គ អ្នកនោះនឹងមិនបំពេញតាមបំណងចិត្តលោភលន់ខាងនិស្ស័យសាច់ឈាមឡើយ (*កាឡាទី ៥:១៦*) ។ ដូច្នេះ យើងផឹកស្រា ឬមិនផឹក ត្រូវតែសម្រេចទៅលើព្រះវិញ្ញាណបរិសុទ្ធណែនាំ មិនមែនដោយមានច្បាប់ ឬមិនមាននោះទេ ។ លើសពីនេះថែមទៀត អ្នកណាប្រព្រឹត្តតាមព្រះវិញ្ញាណណែនាំ អ្នកនោះមិនត្រូវការច្បាប់ដែលថា «កុំឲ្យផឹកគ្រឿងស្រវឹងគ្រប់ប្រភេទ» នោះឡើយ ពីព្រោះ «**ក្រឹត្យវិន័យមិនមែនតាំងសំរាប់មនុស្សសុចរិតទេ គឺសំរាប់មនុស្សទទឹងច្បាប់ និងមនុស្សរឹងចចេស**» វិញ (*១ធីម៉ូថេ ១:៩*) ។ ដូច្នេះ យើងដើរតាមព្រះវិញ្ញាណបរិសុទ្ធ ដែលហាមប្រាមការស្រវឹងជាដាច់ខាតផងផឹកស្រាសម័យនេះ ដែលបណ្តាលឲ្យធាប់ស្រវឹងផង យ៉ាងដូចម្តេចកើត ?

តើយើងនឹងផឹក ឬមិនផឹក ? ការសំរេចចិត្តនេះអាស្រ័យទៅលើយើងម្នាក់ៗដោយខ្លួនឯង ក៏ប៉ុន្តែ បើប្រព្រឹត្តទទឹងទៅនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺព្រះអង្គទេតើ ដែលនឹងចាប់កំហុស ហើយដាក់ទោសក្នុងការវិនិច្ឆ័យរបស់ទ្រង់ ដោយគ្មាននរណាម្នាក់អាចនឹងរំដោះយើងឲ្យរួចសោះឡើយ ! ដូច្នេះហើយ តើយើងគួរគប្បីខ្នះខ្នែងគាប់ចិត្តដល់អ្នកណាជាង ?

សូមឲ្យយើងទាំងអស់គ្នាមានចិត្តគំនិតតែមួយ គឺឲ្យមានការឯកភាព និងសាមគ្គីភាព ដើម្បីសហប្រតិបត្តិការ ខំព្យាយាមរក្សាភាពបរិសុទ្ធរបស់ពួកយើង ដោយយោគយល់ទៅដល់ឈើឆ្កាងរបស់ព្រះគ្រីស្ទចុះ ។ ព្រះអង្គបានសង្គ្រោះយើងឲ្យរួចពីបាប ដោយសារព្រះលោហិតរបស់ព្រះអង្គផ្ទាល់ ប្រយោជន៍ឲ្យយើងបានញែកចេញជាបរិសុទ្ធ ដូចជាព្រះជាម្ចាស់ ទ្រង់បរិសុទ្ធដែរ ។ ដូចជាសាវ័កពេត្រុសបានដាស់តឿនក្រុមជំនុំក្នុងសំបុត្រ ទី១ របស់លោករួចមកហើយ យើងត្រូវតែប្រព្រឹត្ត ៖

> **ដូចជាពួកកូនដែលស្តាប់បង្គាប់ ឥតបណ្តោយតាមសេចក្តីប៉ងប្រាថ្នា ដែលអ្នករាល់គ្នាមាន ពីកាលនៅល្ងង់ពីដើមនោះឡើយ តែចូរឲ្យអ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះដែលហៅអ្នករាល់គ្នា ទ្រង់បរិសុទ្ធដែរ ដ្បិតមានសេចក្តីចែងទុកមកថា «ចូរឲ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ» ។**
>
> *១ពេត្រុស ១:១៤-១៦*

# *ជំពូក ទី៦*
# *អ្នកណាដែលវង្វេងដោយគ្រឿងស្រវឹង ឈ្មោះថា គ្មានប្រាជ្ញា – សុភាសិត ២០:១*

ព្រះគម្ពីរបង្រៀនយើងថា ប្រាជ្ញាជាលក្ខណសម្បត្តិដ៏មានតម្លៃថ្លៃថ្នូរបំផុត ដែលរកអ្វីមួយមកផ្ទឹមឲ្យស្មើពុំបានឡើយ ( *សុភាសិត ៨:១១* ) ។ ប្រាជ្ញាមានតម្លៃដ៏ថ្លៃដូច្នេះ ព្រោះតែវាអប់រំយើងឲ្យចេះងាកចេញទៅឆ្ងាយពីផ្លូវបាប ដោយការកោតខ្លាចដល់ព្រះអម្ចាស់ និងការជំនុំជំរះរបស់ព្រះអង្គ ។ ព្រះគម្ពីរចែងមកថា «**សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃដំរិះ**» ( *សុភាសិត ១:៧* ) ហើយ «**មើលសេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់ នោះហើយជាប្រាជ្ញា ហើយដែលថយឆ្ងាយពីការអាក្រក់ នោះឯងជាយោបល់**» ( *យ៉ូប ២៨:២៨* ) ។ គ្មានទ្រព្យសម្បត្តិអ្វីមានតម្លៃស្មើនឹងប្រាជ្ញា ដែលព្រះអម្ចាស់ប្រទានមកនេះទេ ទោះជាប្រាក់ មាស ពេជ្រ ឬត្បូងផ្សេងៗក៏ដោយ ( *យ៉ូប ២៨:១៥-១៦* ) ។

ដោយសារប្រាជ្ញាមានតម្លៃដ៏ថ្លៃបំផុតដូច្នេះ យើងត្រូវតែចេះការពារខ្លួន ដើម្បីកុំឲ្យបាត់បង់ប្រាជ្ញា ។

**ឧទាហរណ៍ ៖** បើយើងដឹងថា តំបន់មួយគ្រោះថ្នាក់ណាស់ ពីព្រោះសម្បូរជនពាលដូចជាចោរ ឬអ្នកប្រើគ្រឿងញៀន នោះយើងនឹងមិនជិះម៉ូតូកាត់តំបន់នោះនៅពេលយប់ជ្រៅឡើយ ក្រែងលោមានចោរធ្វើបាប និងប្លន់យកទ្រព្យសម្បត្តិដែលជាប់នឹងខ្លួន ។ ផ្ទុយទៅវិញ យើងតែងតែរកផ្លូវវាង ដែលមានសុវត្ថិភាពដើម្បីការពារទាំងខ្លួនផង និងទ្រព្យសម្បត្តិផង ។

ដូចគ្នានេះដែរ ដោយសារប្រាជ្ញាជាលក្ខណសម្បត្តិដ៏មានតម្លៃថ្លៃថ្នូរបំផុតនោះ ដូច្នេះ គ្រីស្ទបរិស័ទក៏ត្រូវចាត់ទុកអ្វីៗទាំងអស់ ដែលមានលទ្ធភាពអាចនឹងប្លន់យកប្រាជ្ញារបស់ខ្លួន ជារបស់គ្រោះថ្នាក់បំផុតដែរ ។ ព្រះគម្ពីរចែងថា «**ស្រាទំពាំងបាយជូរនោះរមែងដកយោបល់ចេញ**» (*ហូសេ ៤:១១*)។ អ្នកណាឲ្យតម្លៃលើប្រាជ្ញា ហើយកោតខ្លាចដល់ព្រះអម្ចាស់ និងការជំនុំជំរះរបស់ព្រះអង្គពិតមែន តើអ្នកនោះនឹងហ៊ានប្រថុយនឹងការបាត់បង់ប្រាជ្ញារបស់ខ្លួន ឬប្រលែងលេងជាមួយនឹងបាបដោយផឹកគ្រឿងស្រវឹងទេឬអី ?

រីឯអ្នកណាដែលប្រព្រឹត្តអំពើបាប ព្រោះតែបាត់បង់ស្មារតីដោយផឹកគ្រឿងស្រវឹង នោះបង្ហាញឲ្យឃើញថា គេមិនឲ្យតម្លៃលើប្រាជ្ញាដែលព្រះអម្ចាស់ប្រទានមក តែសុខចិត្តរស់នៅដោយខ្វះប្រាជ្ញាដដែលៗទៅវិញទេ ។ លើសពីនេះទៅទៀត អ្នកនោះឯងក៏ប្រមាថមាក់ងាយដល់ឈើឆ្កាងរបស់ព្រះគ្រីស្ទថែមទៀតផង ដោយមិនយល់ដល់តម្លៃពេញបរិបូរណ៍នៃសេចក្តីសង្គ្រោះរបស់ទ្រង់ គឺព្រះយេស៊ូវបានស៊ូប្តូរ *ព្រះជន្មរបស់ព្រះអង្គផ្ទាល់*នៅលើឈើឆ្កាងនោះ ប្រយោជន៍នឹងធ្វើឲ្យយើងក្លាយជា «**បរិសុទ្ធ ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន នៅចំពោះទ្រង់**» (*កូឡូស ១:២២*)។ *តើអ្នកឲ្យតម្លៃដល់ព្រះជន្មរបស់ព្រះគ្រីស្ទ ដែលទ្រង់បានស៊ូប្តូរដើម្បីភាពបរិសុទ្ធរបស់អ្នកខ្ពស់ប៉ុណ្ណា?* ដោយសារសាវ័កប៉ុលបានយល់ដល់តម្លៃនៃឈើឆ្កាងរបស់ព្រះគ្រីស្ទហើយ ក៏លោកផ្តែផ្តាំមកយើងថា «**កុំឲ្យផ្គត់ផ្គង់ ដើម្បីនឹងបំពេញសេចក្តីប៉ងប្រាថ្នាខាងឯសាច់ឈាមឡើយ**» (*រ៉ូម ១៣:១៤*)។ ដូច្នេះ យើងត្រូវតែកាត់ចិត្តលះបង់អ្វីៗទាំងអស់ ដែលមានលទ្ធភាពអាចនាំយើងឲ្យប្រព្រឹត្តអំពើបាបវិញ ហើយប្រមាថមាក់ងាយដល់ឈើឆ្កាងរបស់ព្រះគ្រីស្ទបាន ទោះជាអ្វីក៏ដោយ រួមមានគ្រឿងស្រវឹងផងដែរ ។

តើគេស្គាល់ឆ្កែ ឬជ្រូកថា ជាសត្វដែលមានប្រាជ្ញាទេឬអី ? «**ឆ្កែបានត្រឡប់ទៅស៊ីកំអួតវា ឯជ្រូកញីដែលគេលាងស្អាតហើយ បានទៅននៀលនៅក្នុងខ្នាចវិញ**»

(*២ពេត្រុស ២:២២*)។ ដូចជាជ្រូកមិនចេះឲ្យតម្លៃលើទង្វើម្ចាស់របស់វា នៅពេលវាត្រឡប់ទៅភក់ជ្រាំវិញជាយ៉ាងណា ក៏អ្នកដែលទទួលព្រះគ្រីស្ទលាងសំអាតអំពើបាបរបស់ខ្លួនចេញហើយ រួចត្រឡប់ទៅប្រព្រឹត្តអំពើបាបវិញម្តងទៀតដោយផឹកស្រាមិនចេះឲ្យតម្លៃដល់ទង្វើរបស់ព្រះអង្គនៅលើឈើឆ្កាងយ៉ាងនោះដែរ ។ ផ្ទុយទៅវិញគេបង្ហាញថា មិនឲ្យតម្លៃលើភាពបរិសុទ្ធ ដែលព្រះគ្រីស្ទបានទិញឲ្យគេ *ដោយបង់ថ្លៃជាព្រះលោហិតរបស់ព្រះអង្គផ្ទាល់*សោះឡើយ ។ សាវ័កពេត្រុសបានរំឭកយើងថា ប្រសិនបើអ្នកណាបានរួចពីអំពើស្មោកគ្រោករបស់លោកីយ៍ ដោយបានស្គាល់ព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរួចហើយ តែបែរជាបណ្តោយឲ្យអំពើទាំងនោះមកបង្ក្រាបខ្លួនវិញ នោះសភាពរបស់គេនឹងក្លាយទៅជាអាក្រក់ជាងមុនទៅទៀត (*២ពេត្រុស ២:២០*)។ ដូច្នេះ យើងត្រូវតែប្រយ័ត្នខ្លួនជាខ្លាំងណាស់ ដើម្បីកុំឲ្យប្រមាថមាក់ងាយដល់ព្រះលោហិតដ៏ថ្លៃវិសេសរបស់ព្រះគ្រីស្ទ ឬប្រាជ្ញាដ៏ថ្លៃថ្នូរដែលព្រះអម្ចាស់ប្រទានមកដែលបង្រៀនយើងឲ្យចេះចៀសវាងឆ្ងាយពីផ្លូវបាបទៅ ។

មួយវិញទៀត គ្មានការសង្ស័យអ្វីថា ស្រាជាគ្រឿងដ៏ខ្លាំងពូកែមួយ ដែលអាចយកជ័យជម្នះទៅលើឆន្ទៈល្អរបស់មនុស្សបានដោយងាយស្រួល ដូចជាបំណងចង់រាប់អានគេជាដើម ។ ស្រាអាចនឹងចាប់ខ្លួនអ្នក ដែលហាក់ដូចជាមានប្រាជ្ញាវាងវៃឲ្យក្លាយទៅជាឈ្លើយសឹករបស់វា រួចបង្ខំឲ្យបម្រើអំពើបាបគ្រប់បែបយ៉ាង ដោយវាបានប្លន់យកប្រាជ្ញារបស់គេ ។ លុះថ្ងៃជំនុំជំរះមកដល់ អ្នកនោះនឹងប្រឈមមុខនឹងការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ។ ព្រះយេស៊ូវ ដែលទ្រង់ឈ្វេងយល់អំពីចិត្តមនុស្សហើយមានព្រះបន្ទូលប្រាប់មកថា ៖ «**ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន ក្រែងចិត្តអ្នករាល់គ្នាកំពុងតែផ្ទុកនូវសេចក្តីវក់នឹងស៊ីផឹក និងសេចក្តីខ្វល់ខ្វាយនៅជីវិត នោះលោតែថ្ងៃនោះ** [*គឺថ្ងៃជំនុំជំរះ*] **មកដល់អ្នករាល់គ្នាភ្លាម**» (*លូកា ២១:៣៤*)។

គ្រីស្ទបរិស័ទដែលមានប្រាជ្ញាវាងវៃ ដែលមកពីព្រះអម្ចាស់ពិតមែន នឹងធ្វើតាមគំរូរបស់សាវ័កប៉ុល ដោយមិនព្រមចុះចូលចំពោះអំណាចរបស់ស្រានោះឡើយ ដូចលោកបានប្ដេជ្ញាចិត្តថា «**ខ្ញុំមិនព្រមចុះចូលក្នុងអំណាចនៃការណាមួយនោះសោះ**» ( *១កូរិនថូស ៦:១២* ) ។ មានអំណាចតែមួយគត់ ដែលយើងត្រូវចុះចូល គឺជាអំណាចរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ ដូច្នេះ យើងមិនត្រូវស្ថិតក្រោមការត្រួតត្រារបស់គ្រឿងស្រវឹងដូចជាឈ្លើយសឹករបស់វា ហើយត្រូវបម្រើអំពើបាបដោយគ្មានប្រាជ្ញានោះឡើយ ។ សូមពិចារណាព្រះហឫទ័យរបស់ព្រះអម្ចាស់ ដែលព្រះអង្គចង់ឲ្យយើងបានពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងចេះគោរពប្រតិបត្តិតាមព្រះអង្គចុះ ៖

**កុំឲ្យខ្លៅល្ងង់ឡើយ ត្រូវខំឲ្យយល់បំណងព្រះហឫទ័យព្រះអម្ចាស់វិញ កុំឲ្យស្រវឹងស្រាដែលនាំឲ្យព្រើលចិត្តឡើយ តែចូរឲ្យបានពេញជាព្រះវិញ្ញាណវិញ ។**

*អេភេសូរ ៥:១៨*

**តែខ្ញុំប្រាប់ថា ចូរដើរក្នុងព្រះវិញ្ញាណ នោះអ្នករាល់គ្នានឹងមិនបំពេញសេចក្ដីប៉ងប្រាថ្នាខាងសាច់ឈាមទេ ។**

*កាឡាទី ៥:១៦*

**ត្រូវឲ្យយើងដើរតាមដែលគួរគប្បី ដូចជាដើរនៅពេលថ្ងៃ មិនមែនដោយស៊ីផឹកលេងល្បែង ឬមានស្រីញី ឬដោយឈ្លោះប្រកែក និងឈ្នានីសនោះឡើយ គឺត្រូវប្រដាប់ខ្លួន ដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទវិញ ហើយកុំឲ្យផ្គត់ផ្គង់ ដើម្បីនឹងបំពេញសេចក្ដីប៉ងប្រាថ្នាខាងឯសាច់ឈាមឡើយ ។**

*រ៉ូម ១៣:១៣-១៤*

## *ជំពូក ទី៧*
## *បើខ្ញុំផឹកស្រា តើទង្វើនេះអាចនឹងនាំឲ្យ បងប្អូនរួមជំនឿជំពប់ដួលដែរ ឬយ៉ាងណា ?*

អ្នកខ្លះអួតអាងថា ខ្លួនមានសមត្ថភាពអាចផឹកស្រាដោយទប់ចិត្តបាន តែនេះមិនមែនជាគំនិតនៃប្រាជ្ញា ដែលមកពីព្រះអម្ចាស់ឡើយ ។ អ្នកពោលបែបនេះចេះតែគិតពីខ្លួនឯង ចង់ផឹកឲ្យសប្បាយ តែមិនទាន់ចេះស្រឡាញ់ដោយយោគយល់ដល់ប្រយោជន៍របស់អ្នកដទៃនោះទេ ។ ប្រសិនបើបងប្អូនរួមជំនឿដែលទន់ខ្សោយ ឬមិនទាន់មានចំណេះដឹងច្រើនប៉ុន្មានទេ គេសម្លឹងមើលយើងដែលអួតអាងកម្លាំងរបស់ខ្លួនកំពុងតែផឹកគ្រឿងស្រវឹង នោះយើងនឹងជំរុញចិត្តរបស់គេឲ្យហ៊ានផឹក ហើយអ្នកនោះមុខតែនឹងជំពប់ដួលទៅក្នុងអំពើបាបជាមិនខាន ។ ព្រះគ្រីស្ទ ទ្រង់បានសោយទិវង្គតដើម្បីសង្គ្រោះអ្នកនោះឲ្យរួចពីបាបរបស់គេហើយ ប៉ុន្តែ អំនួតរបស់ខ្លួនបែរជានាំឲ្យគេត្រូវវិនាសអន្តរាយទៅវិញ បានសេចក្ដីថា យើងបានធ្វើបាបទៅលើបងប្អូនយើងម្នាក់រួមទាំងលើអង្គព្រះគ្រីស្ទផ្ទាល់ថែមទៀតផង !

ដូចគ្នានេះដែរ ឪពុកម្ដាយណា ដែលនាំកូនរបស់ខ្លួនឲ្យប្រព្រឹត្តអំពើបាបដោយគំរូផឹកគ្រឿងស្រវឹងរបស់ពួកគេ នោះពិតជាមានទោសនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ហើយ ។ ចំពោះអ្នកដែលនាំកូនក្មេងឲ្យជំពប់ដួល ព្រះយេស៊ូវមានព្រះបន្ទូលថា «**ស៊ូឲ្យគេយកថ្មត្បាល់កិនយ៉ាងធំចងកអ្នកនោះ ហើយពន្លង់ទៅក្នុងសមុទ្រជាទីជ្រៅវិញ ធ្វើយ៉ាងនោះនឹងមានប្រយោជន៍ដល់អ្នកនោះជាជាង**» (*ម៉ាថាយ ១៨:៦*) ។ យើងមិនត្រូវធ្វើអ្វីៗទាំងអស់ ដែលអាចនឹងនាំឲ្យកូនក្មេងធ្លាក់ទៅក្នុងអំពើបាបជាដាច់ខាត ដូចជាបង្ហូចគំរូរបស់ខ្លួនដោយផឹកគ្រឿងស្រវឹង ។

ដូច្នេះ ថ្វីបើយើងខំប្រឹងចៀសវាងការស្រវឹងក៏ដោយ ក៏គង់តែការផឹកស្រាគឺជាអំពើដ៏ខ្វះប្រាជ្ញាណាស់ ព្រោះតែខ្លួនបានប្រព្រឹត្តតាមផ្លូវអាត្មានិយម ពុំបានគិតពីប្រយោជន៍របស់អ្នកដទៃសោះ តែបែរជានាំឲ្យគេធ្លាក់ទៅក្នុងអំពើបាបតាមខ្លួនវិញ ព្រមទាំងធ្វើឲ្យគេមានទោសចំពោះព្រះជាម្ចាស់ដោយសារខ្លួនទៀតផង ។ តើអ្នកណាចង់រៀបរាប់ទូលដល់ព្រះជាម្ចាស់ពីអំពើបែបនេះ ដែលខ្លួនបានប្រព្រឹត្តដូច្នេះ ?

ប្រាជ្ញាពិតដែលមកពីព្រះអម្ចាស់មែន ប្រៀនប្រដៅយើងឲ្យចេះលះបង់សិទ្ធិសេរីភាពរបស់ខ្លួន ដើម្បីស្វែងរកប្រយោជន៍សម្រាប់អ្នកដទៃ ដូចជាគំរូរបស់សាវ័កប៉ុលដែរ ៖

> គួរតែកុំឲ្យបរិភោគសាច់ ឬស្រាទំពាំងបាយជូរ ឬអ្វីដែលនាំឲ្យបងប្អូនអ្នកជំពប់ ឬរវាតចិត្ត ឬធ្វើឲ្យខ្សោយនោះឡើយ ។
>
> *រ៉ូម ១៤:២១*

> បើសិនជាចំណីអាហារអ្វី នាំឲ្យបងប្អូនខ្ញុំជំពប់ដួល នោះខ្ញុំមិនព្រមទទួលទានចំណីអាហារនោះជាដរាបតទៅ ក្រែងបងប្អូនខ្ញុំជំពប់ដួល ។
>
> *១កូរិនថូស ៨:១៣*

> កុំឲ្យអ្នកណាស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ ត្រូវរកដល់អ្នកដទៃវិញ ។
>
> *១កូរិនថូស ១០:២៤*

> បងប្អូនអើយ ព្រះ ទ្រង់បានហៅអ្នករាល់គ្នាមក ឲ្យមានសេរីភាព កុំឲ្យប្រើសេរីនោះទុកជាឱកាសដល់សាច់ឈាមឡើយ គឺត្រូវបម្រើគ្នាទៅវិញទៅមក ដោយសេចក្តីស្រឡាញ់វិញ ។
>
> *កាឡាទី ៥:១៣*

លើសពីសេចក្តីទាំងនេះទៅទៀត ព្រះអម្ចាស់ ទ្រង់សព្វព្រះហឫទ័យឲ្យយើងចេះកសាងឡើងបាននូវជំនឿរបស់អ្នកដទៃទៀតផង ៖

**ត្រូវឲ្យយើងដេញតាមអស់ទាំងសេចក្តី ដែលនាំឲ្យមេត្រីគ្នា និងសេចក្តីទាំងប៉ុន្មានដែលជួយស្អាងចិត្តគ្នាទៅវិញទៅមកវិញ ។**

*រ៉ូម ១៤:១៩*

**ត្រូវឲ្យធ្វើការទាំងអស់ សម្រាប់នឹងស្អាងចិត្តឡើង ។**

*១កូរិនថូស ១៤:២៦*

**ត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្តាលឲ្យមានសេចក្តីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង ។**

*ហេព្រើរ ១០:២៤*

បើយើងចង់បង្ហាញថា ស្រឡាញ់បងប្អូននៅក្នុងព្រះគ្រីស្ទ ជាជាងការសប្បាយរបស់ខ្លួន នោះគួរគប្បីតមស្រាតែម្តងទៅ ដើម្បីនឹងកសាងឡើងបាននូវជំនឿរបស់ពួកគេ ។ យើងត្រូវសម្តែងដោយរបៀបរស់នៅរបស់ខ្លួននូវតម្លៃដ៏ពេញលេញនៃឈើឆ្កាងរបស់ព្រះគ្រីស្ទឲ្យពួកគេឃើញ ហើយឲ្យពួកគេរៀនចេះបែរចេញពីអំពើបាប ដើម្បីនឹងប្រព្រឹត្តតាមសេចក្តីសុចរិត និងសេចក្តីបរិសុទ្ធ ដែលព្រះគ្រីស្ទបានទិញឲ្យយើងដោយការបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់ ។

**ចូរត្រាប់តាមព្រះ ដូចជាកូនស្ងួនភ្ងា ហើយដើរក្នុងសេចក្តីស្រឡាញ់ ដូចជាព្រះគ្រីស្ទបានស្រឡាញ់យើង ព្រមទាំងប្រគល់ព្រះអង្គទ្រង់ជំនួសយើងផង ទុកជាដង្វាយ ហើយជាយញ្ញបូជា សម្រាប់ជាក្លិនឈ្ងុយថ្វាយដល់ព្រះ ។**

*អេភេសូរ ៥:១-២*

ដូច្នេះ ដូចជាព្រះគ្រីស្ទ ទ្រង់បានលះបង់ព្រះជន្មរបស់ព្រះអង្គផ្ទាល់ ដើម្បីជាប្រយោជន៍

ដល់យើងរាល់គ្នាជាយ៉ាងណា យើងក៏ត្រូវគ្រាប់តាមព្រះអង្គ ដោយការលះបង់ក្នុងជីវិតរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នកដទៃយ៉ាងនោះដែរ ។ យើងខ្ញុំជឿជាក់ថា អ្នកដែលហ៊ានលះបង់ការផឹកស្រាដោយតម អ្នកនោះនឹងទទួលបានរង្វាន់ដ៏អស់កល្បជានិច្ចពីព្រះអម្ចាស់ជាមិនខាន ពីព្រោះ គេបានរាប់សេចក្តីជំនឿ និងសេចក្តីសង្គ្រោះរបស់អ្នកដទៃ ទុកជាការសំខាន់ជាងការសប្បាយរបស់ខ្លួន ។

រីឯអ្នកណាដែលអួតអាងថា «ខ្លួនមានសមត្ថភាពអាចនឹងផឹកស្រាដោយទប់ចិត្តបាន» សូមយកចិត្តទុកដាក់ នឹងពិចារណាខគម្ពីរដូចខាងក្រោមនេះ ៖

**អ្នកណាដែលស្មានថាខ្លួនឈរ នោះត្រូវប្រយ័ត្ន ក្រែងលោដួល ។**

*១កូរិនថូស ១០:១២*

**សេចក្តីឆ្មើងឆ្មៃនាំមុខសេចក្តីហិនវិនាស ហើយចិត្តព្រហើនក៏នាំឲ្យដួលចុះដែរ ។**

*សុភាសិត ១៦:១៨*

**មានពរហើយ អ្នកណាដែលមិនកាត់ទោសខ្លួនឯង ក្នុងការដែលខ្លួនរាប់ថាធ្វើបាន ។**

*រ៉ូម ១៤:២២*

# *ជំពូក ទី៨*
# *បើខ្ញុំផឹកស្រា តើវាប៉ះពាល់ដល់ព្រះកិត្តិនាមរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេចដែរ?*

ទង្វើរបស់ខ្លួនមិនដែលប៉ះពាល់ត្រឹមតែខ្លួនឯងប៉ុណ្ណោះទេ គឺគ្រប់ទង្វើទាំងអស់ តែងតែប៉ះពាល់អ្នកដទៃ រួមទាំងព្រះជាម្ចាស់ជានិច្ច ។ ដោយព្រោះព្រះអង្គបានបង្កើតមនុស្សមកឲ្យ «**ដូចរូបអង្គទ្រង់**» (*លោកុប្បត្តិ ១:២៧*) ដូច្នេះ មនុស្សយើងទាំងអស់សុទ្ធតែជាតំណាងរបស់ព្រះអង្គហើយ ជាពិសេស អស់អ្នកណាដែលព្រះអង្គបានប្រោសប្រទានឲ្យក្លាយជា «បុត្រធីតារបស់ព្រះបិតា» ក្នុងព្រះគ្រីស្ទ ។ កាលណាគេសម្លឹងមើលសកម្មភាពរបស់យើង គេក៏បានស្គាល់អំពីព្រះបិតាដែរថា ទ្រង់ជាបែបយ៉ាងណាៗ តាមរយៈទង្វើរបស់ខ្លួនក្នុងឈ្មោះជាបុត្រធីតារបស់ព្រះអង្គ ទោះជាការល្អក្ដី ឬការអាក្រក់ក្ដី ។ ដូច្នេះ គ្រប់ការដែលយើងធ្វើទាំងប៉ុន្មាន ត្រូវធ្វើឡើងក្នុងគោលបំណងចង់លើកតម្កើងព្រះកិត្តិនាមរបស់ព្រះអម្ចាស់ ដោយចិត្តស្រឡាញ់ព្រះអង្គ ។

ដូចអ្នកដែលអួតខ្លួនថា «ផឹកស្រាដោយទប់ចិត្តបាន» មិនទាន់ចេះប្រព្រឹត្តដោយយោគយល់ដល់ជំនឿរបស់អ្នកដទៃជាយ៉ាងណា អ្នកនោះឯងក៏មិនទាន់ចេះប្រព្រឹត្តដោយយោគយល់ដល់ព្រះកិត្តិនាមរបស់ព្រះអម្ចាស់យ៉ាងនោះដែរ ។ ព្រះអង្គបានសង្គ្រោះយើងដោយព្រះគុណដ៏ឧត្តមរបស់ទ្រង់ «**ប្រយោជន៍ឲ្យយើង ដែលបានទុកចិត្តជឿដល់ព្រះគ្រីស្ទជាមុន បានសម្រាប់នឹងសរសើរដល់សិរីល្អទ្រង់**» (*អេភេសូរ ១:១២*) ។ សិរីល្អរបស់ព្រះអម្ចាស់ពិតជាឧដុង្គឧត្ដមលើសលប់ក្រៃលែងណាស់ហើយ ព្រះអង្គប្រកបដោយសេចក្ដីបរិសុទ្ធ សេចក្ដីសុចរិត និងយុត្តិធម៌ តាំងពីមុនដើមដំបូង រហូតដល់អស់កល្បជានិច្ច ។ ដូច្នេះ តើយើងត្រូវប្រព្រឹត្តរបៀបណា

ដើម្បីអាចនឹងឆ្លុះបញ្ចាំងអំពីសិរីល្អដ៏ធំអស្ចារ្យរបស់ព្រះអម្ចាស់នេះ ហើយលើកតម្កើងព្រះកិត្តិនាមដ៏ប្រសើរលើសជាងគេបង្អស់របស់ទ្រង់ ដោយកិរិយារបស់ខ្លួន ? ចុះបើការប្រព្រឹត្តដូចខាងក្រោមនេះ តើអ្នកគិតថា វាប៉ះពាល់ដល់ព្រះកិត្តិនាមរបស់ព្រះអម្ចាស់យ៉ាងដូចម្ដេចដែរ ?

- យើងផឹកស្រាក្នុងផ្ទះរបស់ខ្លួនដោយសម្ងាត់ ក៏ប៉ុន្តែ អ្នកជិតខាងឃើញយើងប្រើកូនឲ្យទៅខាងក្រៅទិញវាមក ។ ពេលក្រោយ គេឮសូរគ្រួសាររបស់យើងឈ្លោះគ្នាក្នុងផ្ទះ ហើយមានសំឡេងក្ដុងក្ដាំងជាច្រើនផងដែរ ។

- យើងចូលទៅក្នុងបារជាមួយពួកម៉ាកយើងម្នាក់ ដែលជាអ្នកមិនជឿ ។ មានស្រីៗស្លៀកពាក់សិចស៊ីបម្រើតុ ហើយចាក់ស្រាបៀរក្នុងកែវយើង កំពុងដែលយើងស្ដាប់បទចម្រៀងស្នេហា និងសម្លឹងមើលស្រីស្អាតៗរាំយ៉ាងញាក់សាច់ ។ ពួកម៉ាកយើងនឹកគិតថា «អ្នកជឿលើព្រះយេស៊ូវឡូយណាស់ !» ពីព្រោះបងគាត់ ដែលទើបតែបួសជាសង្ឃ មិនព្រមលួចមកជាមួយនឹងគាត់ពេលនេះទេ ។

- យើងទៅញ៉ាំការគេ ហើយ ភ្ញៀវទាំងអស់នាំគ្នាបើកដបស្រាទំពាំងបាយជូរ និងស្រាវីស្គីដ៏ថ្លៃៗ ដែលគេដាក់លើតុ ។ ដោយយកលេសថា «កុំឲ្យបាត់មិត្ត» យើងដែលជាអ្នកជឿលើព្រះយេស៊ូវតែម្នាក់ឯង ក្នុងចំណោមអ្នកមិនជឿរាប់រយនាក់ក៏រួមចំណែកក្នុងការផឹកស្រាជាមួយនឹងពួកគេដែរ «តែកុំឲ្យផឹកស្រវឹង» ។ មិនយូរប៉ុន្មាន យើងទប់ចិត្តលែងបានទៀត ហើយផឹកជ្រុលឲ្យស្រវឹងដូចគេឯងដែរ ទើបចាប់ផ្ដើមពោលពាក្យជេរប្រមាថ ហើយញ៉ែលេងជាមួយស្រីក្រមុំៗ ដែលបម្រើតុ ។

- នៅពេលរសៀល ស្ត្រីមេផ្ទះម្នាក់លេងល្បែងស៊ីសង ហើយផឹកទឹកត្នោតជូរជាមួយស្រីៗជិតខាងខ្លួន ។ ដល់ល្ងាចហើយ គាត់ចាញ់លុយអស់រលីង នៅផ្ទះរាយប៉ាយកូនៗយំរញ៉េរញ៉ៃពេញផ្ទះ ហើយនាងទទួលប្ដីដែលត្រឡប់មកពីធ្វើការ ដោយមិន

បានរៀបចំបាយទឹកស្រាប់ ។ ប្ដីក៏ខឹងនាង ពីព្រោះគាត់បានធ្វេសប្រហែសនឹងការងារផ្ទះ ជាហេតុនាំឲ្យមានជម្លោះខ្លាំងៗទៀតផង ។ អ្នកជិតខាងទាំងអស់ឃើញច្បាស់លាស់នូវសកម្មភាពរបស់គ្រួសារមួយនេះ ក្នុងឈ្មោះជាអ្នកជឿលើព្រះគ្រីស្ទយេស៊ូវ ។

ចុះពិចារណាមើល៍ ទង្វើបែបនេះ តើវាជាកិរិយាដ៏ថ្លៃថ្នូរ ដែលសមរម្យទៅនឹងឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់ ដែលទ្រង់ប្រកបដោយសិរីរុងរឿងដ៏អស់កល្បដែរឬទេ ? តើមានភាពងងឹតក្នុងព្រះជាម្ចាស់នៅឯណា ? តើព្រះអង្គមិនបរិសុទ្ធដូចមនុស្សដែលស៊ីផឹកនៅពេលយប់ដែរជាយ៉ាងណា ? តើព្រះអង្គមិនមែនប្រសើរជាងជនប្រមឹកហើយមិនគួរឲ្យកោតសរសើរ និងលើកតម្កើងលើសជាងគេបង្អស់ទេឬអី ? ឬមួយតើព្រះជាម្ចាស់នឹងមិនដាក់ទណ្ឌកម្ម ដោយព្រះហឫទ័យក្រេវក្រោធ ដល់អស់អ្នកណាដែលហ៊ានបន្ទាបបន្ថោកដល់ព្រះកិត្តិនាមដ៏វិសុទ្ធរបស់ព្រះអង្គទេ ឬយ៉ាងណា ? តើមានអ្នកណាបន្ទាបបន្ថោកដល់ព្រះកិត្តិនាមដ៏វិសុទ្ធរបស់ព្រះអម្ចាស់ ជាងអ្នកដែលនាំឲ្យអ្នកដទៃគិតឃើញថា ព្រះរបស់យើង ទ្រង់មិនបរិសុទ្ធ ក្នុងព្រះនាមរបស់ព្រះអង្គផ្ទាល់ឬ ? នៅថ្ងៃដែលព្រះគ្រីស្ទយាងមកដល់ក្នុងសិរីរុងរឿងរបស់ព្រះអង្គ ដើម្បីជំរំជំរះលោកីយ៍ទាំងមូលដោយសេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិត អ្នកនោះនឹងត្រូវអាម៉ាស់យ៉ាងខ្លាំងបំផុតនៅចំពោះព្រះភក្ត្ររបស់ព្រះអង្គជាមិនខាន ! យើងមិនត្រូវភ្លេចជាដាច់ខាតថា ព្រះអម្ចាស់ ទ្រង់បានសង្គ្រោះយើង ដោយមានគោលបំណងព្រះហឫទ័យឲ្យគេលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គនោះឯង ( *អេភេសូរ ១:១២* ) ។

យើងដឹងប្រាកដហើយថា បើយើងមិនព្រមផឹកស្រារួមជាមួយពួកម៉ាក ឬអ្នកភូមិឯទៀតៗ នោះនឹងត្រូវរងការចំអកឡកឡឺយពីពួកគេ ហើយត្រូវបាក់មុខជាមិនខាន ។ ពេលកើតមានដូច្នេះ តើយើងគួរគប្បីយោគយល់ដល់កិត្តិយសរបស់ខ្លួនឯង

ឬព្រះនាមដ៏បរិសុទ្ធរបស់ព្រះអម្ចាស់ជាជាង ? សាវ័កពេត្រុសមានប្រសាសន៍ថា ព្រះគ្រីស្ទត្រូវបានគេជេរប្រមាថ និងរងទុក្ខលំបាកជាច្រើន ដើម្បី «**ផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្ដីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ**» ( *១ពេត្រុស ២:២៤* ) ហើយយើងក៏ត្រូវប្រកាន់ចិត្តគំនិតនេះ ដូចជាព្រះអង្គដែរ ( *១ពេត្រុស ៤:១* ) ។ យើងមិនត្រូវតបស្នងទៅនឹងព្រះគុណរបស់ព្រះជាម្ចាស់ ដោយធ្លាក់ទៅក្នុងអំពើបាប ព្រោះតែមិនចេះអត់ធន់នឹងគេបង្ខិតបង្ខំឲ្យផឹកស្រានោះឡើយ ក៏ប៉ុន្តែ ត្រូវចេះអត់ធ្មត់នឹងពាក្យគេជេរប្រមាថ ហើយចេះរងទុក្ខ ដើម្បីព្រះកិត្តិនាមរបស់ព្រះគ្រីស្ទ ដូចជាទ្រង់បានរងទុក្ខដើម្បីពួកយើងរួចជាស្រេចហើយដែរ ។

ចំពោះអំពើដ៏ខិលខូច ដែលពួកខាងលោកីយ៍នេះបានប្រព្រឹត្តទាំងប៉ុន្មាន ដូចជា «**ការចំណូលស្រា ស៊ីផឹកជ្រុល ការប្រមឹក**» ជាដើម សាវ័កពេត្រុសមានប្រសាសន៍ថា «**គេនឹងត្រូវរៀបរាប់ទូលដល់ព្រះវិញ ដែលទ្រង់រៀបនឹងជំនុំជំរះទាំងមនុស្សរស់ និងមនុស្សស្លាប់**» ( *១ពេត្រុស ៤:៣-៥* ) ។ រីឯអស់អ្នកណាដែលហ៊ានរងទុក្ខដើម្បីព្រះគ្រីស្ទ ដោយមិនព្រមចូលរួមក្នុងការប្រព្រឹត្តអំពើដ៏ខិលខូចរបស់លោកីយ៍នោះទេ អស់អ្នកនោះនឹងបានរួមចំណែកក្នុងសិរីល្អជាមួយនឹងព្រះអង្គនៅថ្ងៃដែលទ្រង់យាងត្រឡប់មកវិញជាមិនខាន ៖ «**ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុងកាលដែលសិរីល្អទ្រង់លេចមក**» ( *១ពេត្រុស ៤:១៣* ) ។ យើងមិនត្រូវខ្មាសចំពោះជំហររក្សាភាពបរិសុទ្ធរបស់ខ្លួននោះឡើយ ៖ «**បើរងទុក្ខ ដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាសឲ្យសោះ ចូរសរសើរដំកើងដល់ព្រះ ដោយព្រោះនាមនោះវិញ**» ( *១ពេត្រុស ៤:១៦* ) ។

ដូច្នេះ កុំឲ្យយើងប្រព្រឹត្តអ្វីណាមួយ ដើម្បីការពារកិត្តិយសរបស់ខ្លួន ហើយដោយសារតែធ្វើដូច្នេះ ធ្លាក់ទៅក្នុងអំពើបាប ទាំងបង្ខូចដល់ព្រះកិត្តិនាមដ៏វិសុទ្ធរបស់ព្រះអម្ចាស់នោះឡើយ ។ ចូរឲ្យយើងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ដោយហ៊ានរងទុក្ខតែមួយរយៈពេលខ្លីប៉ុណ្ណោះ ដោយប្រព្រឹត្តអំពើដ៏ល្អដើម្បីព្រះនាមរបស់ទ្រង់វិញ នោះយើងនឹងរួមចំណែកក្នុងសិរីរុងរឿងរបស់ព្រះអង្គ រហូតដល់អស់កល្បតរៀងទៅ ។

# *ជំពូក ទី៩*
# *តើស្រាអាចធ្វើឲ្យចិត្តខ្ញុំបានស្ងប់ក្សេមក្សាន្តបានដែរឬទេ ?*

យើងបានលើកឡើងហើយថា មនុស្សខ្លះផឹកស្រា ដើម្បីបំភ្លេចរឿងរ៉ាវ និងបញ្ហា ដែលកើតមានក្នុងជីវិត ឬដើម្បីកំសាន្តចិត្តរបស់ខ្លួន ។ យើងក៏បានលើកឡើងដែរថា ការផឹកស្រារមែងតែងតែបង្កឲ្យមានរឿង និងបញ្ហាមកក្នុងជីវិតរឹតតែច្រើន ដែលអាក្រក់ជាងមុនទៅទៀត ។ ការនេះមិនសមនឹងហៅថាប្រាជ្ញាសោះ ពីព្រោះវាប្រឆាំងទៅនឹងបំណងចិត្តរបស់ខ្លួន ដែលមិនចង់មានរឿងទេ ថែមទាំងប្រឆាំងទៅនឹងបំណងព្រះហឫទ័យព្រះជាម្ចាស់ ដែលទ្រង់ចង់ឲ្យយើងចេះទុកចិត្តលើព្រះអង្គក្នុងគ្រប់កាលៈទេសៈទាំងអស់ទៀតផង ។

ព្រះជាម្ចាស់ ទ្រង់មានព្រះបន្ទូលសន្យាថា ព្រះអង្គផ្ទាល់នឹងផ្តល់មកយើងនូវ «**សេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត និងជួយការពារចិត្ត និងគំនិតរបស់អ្នករាល់គ្នា ក្នុងព្រះគ្រីស្ទយេស៊ូវ**» (*ភីលីព ៤:៧*) ។ ចំពោះគ្រាលំបាក ព្រះអង្គមានព្រះបន្ទូលថា «**កុំឲ្យមានចិត្តព្រួយឡើយ ពីព្រោះសេចក្តីអំណររបស់ព្រះយេហូវ៉ាជាកម្លាំងនៃអ្នករាល់គ្នា**» (*នេហេមា ៨:១០*) ។ យើងមិនត្រូវការស្រាសម្រាប់កំសាន្តចិត្តទេ ពីព្រោះយើងមានព្រះបន្ទូលនៃព្រះរបស់យើងរួចហើយ ៖ «**នេះហើយជាសេចក្តីកំសាន្តចិត្តដល់ទូលបង្គំ ក្នុងវេលាដែលទូលបង្គំកើតទុក្ខព្រួយ គឺព្រះបន្ទូលទ្រង់បានប្រោស ឲ្យទូលបង្គំមានកម្លាំងឡើង**» (*ទំនុកតម្កើង ១១៩:៥០*) ។ លើសអស់ទាំងសេចក្តីនេះទៅទៀត យើងក៏មានព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ផ្ទាល់ ដែលទ្រង់គង់នៅជាមួយ សម្រាប់ជាជំនួយរបស់យើងផងដែរ (*យ៉ូហាន ១៤:១៦-១៧*) ។

ចុះជំនួយដែលព្រះជាម្ចាស់ផ្គត់ផ្គង់មកយើងទាំងនេះ តើវាអន់ ឬខ្វះខាតពេកដល់ម្ល៉េះបានជាយើងត្រូវរកស្រាជាជំនួយមួយថែមទៀតទេឬអី ? តើជំនួយដែលព្រះអង្គប្រទានមក វាមិនល្មមនឹងអាចជួយយើងយ៉ាងពិតប្រាកដក្នុងការនឿយព្រួយ ឬនៅគ្រាលំបាកបានទេឬ ? បើយើងពឹងផ្អែកទៅលើស្រា ជំនួសសេចក្ដីសុខសាន្ត អំណរ និងកម្លាំងដែលព្រះជាម្ចាស់ប្រទានមកដោយព្រះអង្គផ្ទាល់ តាមរយៈព្រះបន្ទូល និងព្រះវិញ្ញាណរបស់ទ្រង់ ការនេះនឹងមិនឆ្លុះបញ្ចាំងអំពីព្រះអំណោយទានរបស់ព្រះអង្គថា វាហាក់ដូចជាអន់ពេកនោះឡើយ ។ ផ្ទុយទៅវិញ វាបង្ហាញឲ្យឃើញច្បាស់លាស់ថា គឺជំនឿរបស់ខ្លួនទេតើ ដែលពិតជាអន់ណាស់ និងពិតជានៅទន់ខ្សោយនៅឡើយ ពីព្រោះយើងមិនទាន់ចេះទុកចិត្តលើព្រះអម្ចាស់ទាំងស្រុង ។ ព្រះអង្គមានព្រះបន្ទូលសន្យាថា «**គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកម្លាំងអញបានពេញខ្នាត ដោយសេចក្ដីកម្សោយ**» (*២កូរិនថូស ១២:៩*) ។ បើសិនជាយើងរកស្រាដើម្បីបំភ្លេចរឿងរ៉ាវ ជាជាងទុកចិត្តលើព្រះអម្ចាស់ដោយភ្លឺស្វាង ហើយសង្ឃឹមទៅលើជំនួយដែលទ្រង់ប្រទានមកនោះ បានសេចក្ដីថា យើងប្រមាថមាក់ងាយដល់ព្រះគុណរបស់ព្រះអង្គហើយ ។

ព្រះជាម្ចាស់មិនដែលលះបង់កូនរបស់ព្រះអង្គចោលឡើយ ។ យើងអាចទុកចិត្តលើព្រះអង្គក្នុងគ្រប់ការទាំងអស់ ដោយចិត្តស្ងប់ក្សេមក្សាន្តបាន ទោះជាយ៉ាងណាក៏ដោយ ។ ព្រះជាម្ចាស់ ទ្រង់ជាថ្មដា និងបន្ទាយដ៏ពិតតែមួយ ដែលយើងអាចពឹងជ្រកជានិច្ចបាន ។ ស្រាគ្មានអ្វីល្អ ដែលអាចនឹងបន្ថែមលើព្រះគុណរបស់ព្រះជាម្ចាស់ទាល់តែសោះ ។ ផ្ទុយទៅវិញ ស្រាបានតែបង្អន់ដល់អស់ទាំងជំនួយដែលព្រះអង្គប្រទានមកយើង ក្នុងគ្រាដែលយើងត្រូវការជំនួយនោះឯង រួមទាំងធ្វើឲ្យជីវិតរបស់ខ្លួនរឹតតែវេទនាខ្លាំងឡើងៗទៅវិញទេ ។

ឯគ្រឿងស្រវឹង នឹងទៅជាល្វីង ដល់អស់អ្នកដែលធ្លាប់ផឹក ។

*អេសាយ ២៤:៩*

ឯអ្នកណាដែលមានគំនិតជាប់តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះ ឲ្យមានសេចក្តីសុខពេញខ្នាត ដោយព្រោះគេទុកចិត្តនឹងទ្រង់ ។

*អេសាយ ២៦:៣*

“ខ្ញុំទុកសេចក្តីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកីយ៍ឲ្យទេ ។ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ” ។

*យ៉ូហាន ១៤:២៧*

កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឲ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង ។ យ៉ាងនោះ សេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត និងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នា ក្នុងព្រះគ្រីស្ទយេស៊ូវ ។

*ភីលីព ៤:៦-៧*

# *ជំពូក ទី១០*
# *កាតព្វកិច្ចរបស់គ្រូៗក្នុងក្រុមជំនុំចំពោះបញ្ហាស្រា*

ព្រះគម្ពីរចែងមកថា «**បងប្អូនអើយ កុំឲ្យធ្វើជាគ្រូច្រើនគ្នាពេកឡើយ ពីព្រោះដឹងហើយថា យើងនឹងត្រូវទោសធ្ងន់ជាងគេ**» (*យ៉ាកុប ៣:១*) ។ ខគម្ពីរនេះមិនមែនមានន័យថា មានពីរកំរិត ហាក់ដូចជាមានកំរិតមួយសម្រាប់ក្រុមជំនុំជាទូទៅដែលធូរជាង និងកំរិតមួយផ្សេងទៀត ដែលតឹងរ៉ឹងជាងសម្រាប់គ្រូៗនោះឡើយ ។ ផ្ទុយទៅវិញមានកំរិតតែមួយសម្រាប់អ្នកជឿលើព្រះយេស៊ូវទាំងអស់គ្នា ទោះជាក្រុមជំនុំធម្មតាក្តី ឬគ្រូក្តី គឺគ្មានភាពខុសគ្នាឡើយ ។ ដូច្នេះ ទាំងគ្រូ ទាំងក្រុមជំនុំត្រូវចេះស្តាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះអម្ចាស់ដូចគ្នា ។ ក៏ប៉ុន្តែ ខគម្ពីរនេះបង្ហាញថា ការវិនិច្ឆ័យរបស់ព្រះអង្គចំពោះគ្រូៗ នឹងមានភាពតឹងរ៉ឹងជាងគេទៅតាមកំរិតដដែល ។

ហេតុអ្វីបានជាគ្រូៗនឹងត្រូវព្រះអម្ចាស់វិនិច្ឆ័យតឹងរ៉ឹងជាងគេដូច្នេះ ? ពីព្រោះពួកគេមានកាតព្វកិច្ចធំជាងគេ ដោយសារជាអ្នកដឹកនាំការប្រព្រឹត្តរបស់ហ្វូងចៀមនៃព្រះអង្គទាំងអស់ ។ ប្រសិនបើគ្រូគង្វាលប្រព្រឹត្តល្អត្រឹមត្រូវទៅតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ ហើយធ្វើជាគំរូដ៏ល្អ ដែលក្រុមជំនុំទុកចិត្ត និងអាចយកតម្រាប់តាមបាន នោះទាំងគ្រូ ទាំងក្រុមជំនុំនឹងទទួលបានការសរសើរពីព្រះអង្គនៅថ្ងៃជំនុំជំរះនោះ ។ ក៏ប៉ុន្តែ បើសិនជាគ្រូគង្វាលធ្វេសប្រហែសនៅក្នុងកាតព្វកិច្ចរបស់ខ្លួនចំពោះព្រះអម្ចាស់ ហើយហ្វូងចៀមរបស់ព្រះអង្គវង្វេងទៅតាមគំរូមិនល្អរបស់គាត់ នោះនៅថ្ងៃជំនុំជំរះគ្រូនឹង «**ត្រូវទោសធ្ងន់ជាង**» ក្រុមជំនុំទៅទៀត ពីព្រោះខ្លួនបាននាំប្រជារាស្ត្រដ៏បរិសុទ្ធរបស់ព្រះអម្ចាស់ជាច្រើននាក់ ឲ្យប្រព្រឹត្តខុសពីព្រះហឫទ័យរបស់ព្រះអង្គ ។ ការនេះគួរឲ្យភ័យខ្លាចណាស់ !

អ្នកដឹកនាំត្រូវតែប្រុងប្រយ័ត្នឲ្យមែនទែន ចំពោះការប្រព្រឹត្តរបស់ខ្លួននៅមុខក្រុមជំនុំ ក្រែងលោព្រះអម្ចាស់វិនិច្ឆ័យ ហើយនិងចាប់កំហុស ។ ក្នុងកណ្ឌ១កូរិនថូស ៣ សាវ័កប៉ុលបានប្រៀបក្រុមជំនុំទៅនឹងព្រះវិហាររបស់ព្រះជាម្ចាស់ផ្ទាល់ ដែលកំពុងសាងសង់ឡើងពីលើអង្គព្រះគ្រីស្ទយេស៊ូវ ដែលទ្រង់ជាគ្រឹះរបស់វា ។ ព្រះវិហារនេះ (គឺជាក្រុមជំនុំ) ជាទីសក្ការៈស័ក្តិសមនឹងយាងព្រះវិញ្ញាណដ៏បរិសុទ្ធមកសណ្ឋិត ។ តើយើងជាគ្រូ កំពុងសង់អ្វីពីលើគ្រឹះរបស់ព្រះវិហារនេះ ? លោកប៉ុលបានពន្យល់ថា ៖

**បើអ្នកណាយកមាស ប្រាក់ ត្បូង ឈើ ស្បូវ ឬស្លឹក ដើម្បីនឹងធ្វើពីលើជើងជញ្ជាំងនេះ នោះការដែលអ្នករាល់គ្នាធ្វើ នឹងលេចមកឲ្យឃើញ ដ្បិតថ្ងៃនោះ** [*គឺជាថ្ងៃជំនុំជំរះ*] **នឹងបង្ហាញពីការនោះយ៉ាងច្បាស់លាស់ ព្រោះការនោះនឹងសំដែងចេញមកដោយសារភ្លើង ហើយភ្លើងនឹងសាកមើលការដែលនីមួយៗធ្វើ ឲ្យដឹងជាយ៉ាងណា បើការដែលអ្នកណាសង់ឡើងបានជាប់នៅ អ្នកនោះនឹងបានរង្វាន់ បើការដែលអ្នកណាធ្វើត្រូវឆេះ អ្នកនោះនឹងត្រូវខាតវិញ តែខ្លួនអ្នកនោះនឹងបានរួចបែបដូចជាដើរកាត់ភ្លើង ។**

*១កូរិនថូស ៣:១២-១៥*

ដូច្នេះ យើងទាំងអស់គ្នានឹងត្រូវទទួលខុសត្រូវចំពោះអ្វីៗ ដែលយើងបានធ្វើពីលើក្រុមជំនុំ គឺជាព្រះវិហាររបស់ព្រះជាម្ចាស់ ។ បើដាក់អ្វីល្អៗ ដែលព្រះអង្គសព្វព្រះហឫទ័យ ហើយចាត់ទុកថា ស័ក្តិសមនឹងយាងព្រះវិញ្ញាណដ៏បរិសុទ្ធមកសណ្ឋិត យើងក៏នឹងទទួលបានរង្វាន់ដ៏មានតម្លៃថ្លៃណាស់ ព្រមទាំងបានខ្ពស់មុខខ្ពស់មាត់ចំពោះព្រះភក្ត្រព្រះអង្គថែមទៀតផង ពីព្រោះ «**គ្រប់គ្នានឹងបានសេចក្តីសរសើរពីព្រះរៀងខ្លួន**» ( *១កូរិនថូស ៤:៥* ) ។ ផ្ទុយទៅវិញ បើធ្វេសប្រហែស ដោយដាក់អ្វីៗមិនល្អ ដែលព្រះជាម្ចាស់មិនសព្វព្រះហឫទ័យ ហើយចាត់ទុកថាថោកទាប មិនស័ក្តិសមនឹង

ឋានៈព្រះវិញ្ញាណដ៏បរិសុទ្ធទេ នោះយើងនឹងត្រូវខាតបង់រង្វាន់ រួមទាំងត្រូវអាម៉ាស់មុខចំពោះព្រះភក្ត្រព្រះអង្គថែមទៀតផង ដោយសារតែទង្វើរបស់ខ្លួនឯង ។

ដោយសារមូលហេតុទាំងប៉ុន្មានខាងលើនេះ ទើបយើងត្រូវល្បងមើលចិត្តបុរសមុននឹងតែងតាំងជាគ្រូ ដើម្បីឲ្យដឹងថា គេមានសមត្ថភាព នឹងអាចដឹកនាំក្រុមជំនុំទៅតាមព្រះហឫទ័យព្រះជាម្ចាស់បាន ឬមិនបាន ។ សាវ័កប៉ុលបានលាតត្រដាងនូវគុណសម្បត្តិផ្សេងៗ ដែលអ្នកដឹកនាំក្រុមជំនុំត្រូវតែបំពេញ មុននឹងឡើងជាគ្រូបាន ។ ចំពោះរឿងស្រា លោកផ្តែផ្តាំថា អ្នកដឹកនាំក្រុមជំនុំ «**មិនត្រូវជាអ្នកចំណូលស្រា**» (*១ធីម៉ូថេ ៣:២-៣ និងទីតុស ១:៧*) ។ មនុស្សខ្លះគិតស្មានថា ខនេះអនុញ្ញាតឲ្យអ្នកដឹកនាំក្រុមជំនុំអាចផឹកស្រាគ្រប់ប្រភេទតាមចិត្តចង់ផឹកក៏បាន កុំឲ្យតែចូលចិត្តជ្រុល ឬផឹកឲ្យស្រវឹង ។ ក៏ប៉ុន្តែ យើងមិនត្រូវគិតហួសពីគោលបំណងរបស់សាវ័កប៉ុលនោះឡើយ ។ លោកបានសរសេរសេចក្តីនេះចំពោះស្រាទំពាំងបាយជូរ ដែលខ្លួនលោកធ្លាប់ស្គាល់តែប៉ុណ្ណោះ នៅវេលាដែលលោកនៅមានជីវិតនៅឡើយ ។ ស្រាទំពាំងបាយជូរនោះបានធ្វើដោយធម្មជាតិ ហើយគេតែងតែបន្សាបជាតិអាល់កុលក្នុងវា ដោយប្រើវិធីលាយជាមួយនឹងទឹកជានិច្ច ។ ដូច្នេះ ជាធម្មតា អ្នកផឹកស្រាទំពាំងបាយជូរបុរាណដោយប្រើវិធីនេះ គឺមិនត្រូវស្រវឹងទេ លុះត្រាតែផឹកវាច្រើននិងយូរ ទើបស្រវឹង ។ ហេតុនេះហើយបានជា នៅគ្រានោះ សាវ័កប៉ុលគ្រាន់តែមានប្រសាសន៍ថា «**មិនត្រូវចំណូលស្រា**» បានហើយ ។ រីឯគ្រឿងស្រវឹងបច្ចុប្បន្ន ដែលលោកប៉ុលមិនដែលធ្លាប់ស្គាល់នោះ បើសិនជាផឹកតែពីរ ឬបីកែវប៉ុណ្ណោះ ក្នុងរយៈពេលខ្លី នោះត្រូវស្រវឹងហើយ ពីព្រោះ គេផលិតវា ដើម្បីផឹកក្នុងគោលបំណងឲ្យស្រវឹងនោះឯង ។

គោលបំណងរបស់សាវ័កប៉ុលក្នុងខគម្ពីរខាងលើនេះ គឺមិនមែនគាំទ្រចំពោះការផឹកស្រាគ្រប់ប្រភេទនោះឡើយ ថ្វីបើមនុស្សខ្លះចង់បំពានលើពាក្យសម្តីរបស់លោក ដើម្បីឲ្យមានអត្ថន័យបែបនេះក៏ដោយ ។ ផ្ទុយទៅវិញ តាមខ្លឹមសារជាក់ស្តែងនៃខនេះ

គោលបំណងរបស់សាវ័កប៉ុល គឺឲ្យក្រុមជំនុំបញ្ជាក់ជាមុនថា អ្នកដឹកនាំក្រុមជំនុំមិនចេះស្រវឹងស្រាសោះឡើយ មុននឹងតែងតាំងគេជាគ្រូ ។ ដូចយើងបានបង្ហាញខាងលើរួចមកហើយ ព្រះគម្ពីរមិនអនុញ្ញាតឲ្យគ្រីស្ទបរិស័ទស្រវឹងស្រាដាច់ខាត ជាពិសេសគ្រូគង្វាល ដែលត្រូវតែធ្វើជាគំរូដ៏ល្អដល់ក្រុមជំនុំ ។ ចុះបើសិនជាយើងយកពាក្យសម្ដីរបស់សាវ័កប៉ុលចំពោះស្រាទំពាំងបាយជូរបុរាណមក អនុវត្តឲ្យគាំទ្រចំពោះការផឹកស្រាសម័យនេះ ដែលរមែងនាំឲ្យស្រវឹងវិញ ដោយខុសពីគោលបំណងរបស់លោកដូច្នេះ តើនេះជាការត្រឹមត្រូវ និងយុត្តិធម៌ដែរឬទេ ? ប្រសិនបើសាវ័កប៉ុលបានស្គាល់គ្រឿងស្រវឹងបច្ចុប្បន្នដែលខ្លាំងជាង ហើយផលិត និងផឹកដើម្បីឲ្យស្រវឹង តើគួរជឿថា លោកនឹងគាំទ្រដែរឬទេ ? ប្រាកដជាមិនគាំទ្រសោះ ! យើងមិនអាចប្រើខគម្ពីរខាងលើ ដើម្បីសំអាងថា សាវ័កប៉ុលគាំទ្រឲ្យអ្នកដឹកនាំក្រុមជំនុំផឹកគ្រឿងស្រវឹងបច្ចុប្បន្នបានឡើយ ។ ដូច្នេះ អស់អ្នកណាដែលផឹកវា អ្នកនោះគឺបានគាំទ្រដោយខ្លួនឯង និងលោកីយ៍ដ៏ងងឹតនេះតែប៉ុណ្ណោះ ។

ប្រសិនបើគ្រូណាម្នាក់មានចិត្ត ចង់ធ្វើតាមគោលបំណងរបស់សាវ័កប៉ុលពិតមែននោះ គឺបញ្ជាក់ថា ខ្លួននឹងមិនចេះស្រវឹងស្រាជាដាច់ខាតដូច្នេះ នោះគ្មានវិធីណាដែលច្បាស់លាស់ជាងការតមស្រានោះឡើយ ។ ម៉្យាងវិញទៀត ការយកពាក្យសម្ដីរបស់សាវ័កប៉ុលក្នុងខគម្ពីរខាងលើ មកគាំទ្រការផឹកគ្រឿងស្រវឹងបច្ចុប្បន្ន ដើម្បីឲ្យខ្លួនបានផឹក គឺជាការលាក់ពុតដ៏ធំមួយ បន្លំធ្វើជាគោរពពាក្យរបស់លោក តែការប្រព្រឹត្តផ្ទុយទៅនឹងគោលបំណងរបស់លោកសម្រាប់ពាក្យទាំងនោះឯង ។ វាក៏ជាការប្រព្រឹត្តប្រឆាំងទៅនឹងគោលការណ៍ដ៏សំខាន់មួយនៃជំនឿរបស់យើង ដែលលើកឡើងថាប្រជារាស្ត្រដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់មិនត្រូវស្រវឹងស្រាជាដាច់ខាតថែមទៀតផង ។

មួយវិញទៀត សាវ័កប៉ុលបានសរសេរមកក្រុមជំនុំនៅទីក្រុងអេភេសូរថា គ្រូៗជាព្រះអំណោយទានដ៏ពិសេស ដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទបានប្រទានមក

ក្រុមជំនុំ ។ គ្រូៗត្រូវមានតួនាទីរៀបចំក្រុមជំនុំឲ្យបាន «**គ្រប់លក្ខណ៍**» ដើម្បីឲ្យពួកគេចេះកសាងជំនឿគ្នាទៅវិញទៅមក រហូតដល់គ្រប់គ្នាក្លាយទៅជាមនុស្សពេញវ័យ ឡើងដល់ខ្នាតកម្ពស់របស់ព្រះគ្រីស្ទ (ការសង្ខេបអំពី *អេភេសូរ ៤:១១-១៣*) ។

ក្នុងជំពូកមុនៗ យើងបានឃើញហើយថា ព្រះជាម្ចាស់ ទ្រង់សព្វព្រះហឫទ័យឲ្យយើងចេះរក្សាភាពបរិសុទ្ធរបស់ខ្លួន ព្រោះតែយល់ដល់តម្លៃដ៏ពេញលេញនៃឈើឆ្កាងរបស់ព្រះគ្រីស្ទ មិនព្រមធ្វើឲ្យខ្លួនប្រឡាក់ដោយអំពើបាបទៀតឡើយ ។ យើងក៏ត្រូវកាត់ចិត្តលះបង់សិទ្ធិសេរីភាពរបស់ខ្លួន ឲ្យបានចម្រើនសិរីរុងរឿងរបស់ព្រះជាម្ចាស់ក្នុងគ្រប់ការទាំងអស់ ហើយឲ្យបានជួយកសាងឡើងនូវជំនឿរបស់អ្នកដទៃផងដែរ ។ ប្រជារាស្ត្រដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់ ត្រូវចេះយកព្រះអង្គជាទីពឹងជ្រក និងជាទីកំសាន្តចិត្តរបស់ខ្លួនតែមួយគត់ ក្នុងគ្រប់គ្រាលំបាក ។ យើងក៏បានឃើញក្នុងជំពូកនេះដែរថា គ្រូៗនឹង «**ត្រូវទោសធ្ងន់ជាងគេ**» ព្រោះតែពួកគេមានកាតព្វកិច្ចធំជាងគេ គឺត្រូវតែដឹកនាំក្រុមជំនុំទាំងអស់ ឲ្យប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ គ្រូៗត្រូវធ្វើជាគំរូដ៏ល្អ ដែលក្រុមជំនុំទុកចិត្ត និងអាចយកតម្រាប់តាមបាន ។ គ្រូៗក៏ត្រូវកសាងក្រុមជំនុំ (គឺជាព្រះវិហាររបស់ផងព្រះជាម្ចាស់) ឲ្យបានស័ក្តិសមនឹងយាងព្រះវិញ្ញាណដ៏បរិសុទ្ធមកសណ្ឋិត តាមព្រះហឫទ័យរបស់ព្រះអង្គផងដែរ ។

ដូច្នេះហើយ គ្រូគង្វាលផ្ទាល់ត្រូវតែធ្វើតាមទាំងអស់នេះខ្លួនឯងជាមុនសិន ទើបគាត់អាចរៀបចំក្រុមជំនុំឲ្យបាន «**គ្រប់លក្ខណ៍**» ដើម្បីចេះកសាងជំនឿគ្នាទៅវិញទៅមក រហូតដល់គ្រប់គ្នាក្លាយទៅជាមនុស្សពេញវ័យ ឡើងដល់ខ្នាតកម្ពស់របស់ព្រះគ្រីស្ទបាន ។ ក្រុមជំនុំមិនអាចធ្វើអ្វីៗបានប្រសើរជាងគ្រូរបស់ពួកគេឡើយ ពីព្រោះ «**សិស្សមិនមែនលើសជាងគ្រូទេ តែអ្នកណាដែលបានគ្រប់លក្ខណ៍ នោះនឹងបានដូចជាគ្រូដែរ**» (*លូកា ៦:៤០*) ។

ចុះប្រសិនបើគ្រូបែរជាយកការសប្បាយជាជាង ដោយហ៊ានផឹកគ្រឿងស្រវឹង ដើម្បីកំសាន្តចិត្តវិញ ហើយលទ្ធផលគឺនាំឲ្យក្រុមជំនុំជំពប់ដួលទៅក្នុងអំពើបាបតាមខ្លួន តើធ្វើដូចម្ដេចនឹងនាំឲ្យក្រុមជំនុំបានបរិសុទ្ធ គ្រប់លក្ខណ៍ និងបានទៅជាមនុស្សពេញវ័យក្នុងជំនឿ ដល់ខ្នាតពេញនៃកម្ពស់របស់ព្រះគ្រីស្ទកើត ? ពុំកើតសោះ ! យ៉ាងណាមិញ គ្រូបានតែរុះរើព្រះវិហាររបស់ព្រះជាម្ចាស់ គឺជាក្រុមជំនុំ ឲ្យខ្ទេចខ្ទីអស់ទៅវិញទេ ! ទង្វើបែបនេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់លាស់ហើយថា ខ្លួនខ្វះគុណសម្បត្តិត្រឹមត្រូវហើយ និងមិនស័ក្ដិសមឲ្យបំពេញមុខងារជាអ្នកបម្រើរបស់ព្រះជាម្ចាស់នោះឡើយ ព្រោះតែមិនចេះឃ្វាលហ្វូងចៀមតាមអស់ទាំងមាគ៌ារបស់ព្រះអង្គទេ ។ ប្រសិនបើយើងប្រព្រឹត្តបែបដូច្នេះ ក្នុងតំណែងជាអ្នកដឹកនាំក្រុមជំនុំ ដែលនឹងត្រូវព្រះជាម្ចាស់វិនិច្ឆ័យយ៉ាងតឹងរ៉ឹងជាងនោះ គួរឲ្យភ័យតក់ស្លុតជាខ្លាំង ! «**បើអ្នកណាបង្ខូចព្រះវិហារនៃព្រះ នោះព្រះនឹងធ្វើឲ្យអ្នកនោះត្រូវខូចដែរ ដ្បិតព្រះវិហារនៃព្រះជាវត្ថុដ៏បរិសុទ្ធ គឺជាខ្លួនអ្នករាល់គ្នានេះឯង**» ( *១កូរិនថូស ៣:១៧* ) ។ តើអ្នកណាហ៊ានបង្ខូចព្រះវិហារដ៏បរិសុទ្ធរបស់ផងព្រះជាម្ចាស់នេះ ?

ឱ ! លោកគ្រូអធិប្បាយ គ្រូផ្សព្វផ្សាយដំណឹងល្អ គ្រូគង្វាល និងគ្រូបង្រៀនអើយ គ្រប់គ្នាសុទ្ធតែជាព្រះអំណោយទានដ៏វិសេសពីព្រះគ្រីស្ទដល់ក្រុមជំនុំ ដែលព្រះអង្គបានប្រទានមក ដើម្បីចម្រើនសិរីរុងរឿងរបស់ព្រះអង្គផ្ទាល់ ។ សូមឲ្យគ្រប់គ្នាមេត្តាប្ដេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់តមគ្រឿងស្រវឹងទៅ ដើម្បីឲ្យបានជួយកសាងឡើងនូវព្រះវិហាររបស់ផងព្រះជាម្ចាស់ គឺជាក្រុមជំនុំ ហើយឲ្យធ្វើជាគំរូដ៏ល្អដល់ហ្វូងចៀមរបស់ព្រះអង្គផងដែរ លុះ «**កាលណាមេពួកអ្នកគង្វាលបានលេចមក នោះនឹងទទួលភួងជ័យ ដែលមិនចេះស្រពោនឡើយ**» ( *១ពេត្រុស ៥:៣-៤* ) ។ សូមឲ្យគ្រប់គ្នាយកគោលបំណងរបស់សាវ័កប៉ុលនេះ មកធ្វើជាគោលបំណងរបស់ខ្លួនចុះ ៖ «**ចូរត្រាប់តាមខ្ញុំ ដូចជាខ្ញុំបានត្រាប់តាមព្រះគ្រីស្ទដែរ**» ( *១កូរិនថូស ១១:១* ) ។

# *ជំពូក ទី១១*
# *ប្រសិនបើខ្ញុំមិនផឹកស្រាទេ តើត្រូវធ្វើដូចម្ដេច នៅពេលដែលគេអញ្ជើញខ្ញុំទៅចូលរួមក្នុងពិធី ?*

គ្រីស្ទបរិស័ទជាច្រើននាក់ជឿថា ពួកគេមិនត្រូវផឹកស្រានោះឡើយ ហើយនៅពេលណាដែលពួកគេផឹក វាប៉ះពាល់យ៉ាងខ្លាំងទៅដល់មនសិការរបស់ខ្លួន ។ ប៉ុន្តែពួកគេមួយចំនួនពុំចេះបដិសេធ មិនព្រមផឹកស្រា នៅពេលដែលគេទៅញ៉ាំការ ឬមានគេអញ្ជើញទៅចូលរួមក្នុងពិធីជប់លៀងនោះទេ ។ ដូចបានលើកឡើងតាំងពីជំពូក ទី១ មកម្ល៉េះ យើងដឹងប្រាកដហើយថា យើងនឹងត្រូវប្រឈមមុខនឹងការបៀតបៀន ឬត្រូវគេចំអកឡកឡឺយដាក់យើង បើមិនព្រមផឹកស្រារួមជាមួយពួកគេនោះទេ ។ ដូច្នេះ តើយើងគួរធ្វើយ៉ាងដូចម្ដេច ?

ទីមួយ យើងមិនត្រូវទៅកន្លែងណាដែលដឹងថា នឹងមានគេបង្ខិតបង្ខំឲ្យផឹកស្រានោះឡើយ ប្រសិនបើអាចចៀសវាងបាន ។ ប្រហែលជាយើងមានពួកម៉ាកដែលតែងតែបបួលយើងឲ្យទៅផឹកជាមួយនឹងគាត់ ។ បើគាត់មិនព្រមឈប់បបួលទេ នោះយើងគួរតែជ្រើសរើសពួកម៉ាកផ្សេងទៀតវិញ ពីព្រោះ «**អ្នកណាដែលដើរជាមួយនឹងមនុស្សប្រាជ្ញា នោះនឹងមានប្រាជ្ញាដែរ តែអ្នកណាដែលភប់ប្រសព្វនឹងមនុស្សល្ងីល្ងើ នោះនឹងត្រូវខូចបង់វិញ**» (*សុភាសិត ១៣:២០*) ។ បើសិនជាយើងកំពុងតែព្យាយាមផ្ដាច់ស្រា ឬធ្លាប់ញៀន នោះល្អជាងយើងឲ្យនរណាម្នាក់ផ្សេងទៀតក្នុងគ្រួសារទៅពិធីជំនួសយើងវិញ ដូចជាប្រពន្ធ ឬកូនជាដើម ។ បើយើងជឿជាក់នៅក្នុងដួងចិត្តរបស់ខ្លួនហើយថា ព្រះជាម្ចាស់ ទ្រង់មិនសព្វព្រះហឫទ័យឲ្យយើងផឹកស្រាទេ នោះត្រូវធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីចៀសវាងពីស្ថានភាពណាមួយ ដែលអាចនាំឲ្យយើងផឹកជំទាស់

ទៅនឹងមនសិការរបស់ខ្លួនបាន ។ «**តែបើអ្នកណាបរិភោគទាំងសង្ស័យ នោះមានទោសហើយ ពីព្រោះមិនបានបរិភោគដោយសេចក្តីជំនឿ ដ្បិតការទាំងប៉ុន្មានដែលធ្វើដោយឥតមានសេចក្តីជំនឿ នោះសុទ្ធតែជាបាបទាំងអស់ហើយ**» (*រ៉ូម ១៤:២៣*) ។

ទោះជាយ៉ាងណាក៏ដោយ ជួនកាលយើងចៀសវាងមិនបាន ត្រូវចូលរួមក្នុងពិធីការ ឬពិធីផ្សេងៗទៀត ដែលនឹងមានមនុស្សជាច្រើនផឹកស្រា ។ នៅពេលដែលកើតមានដូច្នេះ *តើយើងបដិសេធ មិនព្រមផឹកស្រាដោយរបៀបណា ដែលអាចនឹងប្រកាន់កិរិយាត្រឹមត្រូវក្នុងព្រះគ្រីស្ទ ហើយរក្សាទីបន្ទាល់របស់ខ្លួនបាន?*

*ត្រៀមចិត្តគំនិតទុក មុននឹងទៅក្នុងពិធី ៖*

- ត្រូវប្តេជ្ញាចិត្តធ្វើគ្រប់អ្វីៗទាំងអស់ ឲ្យបានគាប់ដល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាជាងដល់ចិត្តមនុស្សមានបាប ៖ «**បើសិនជាខ្ញុំចង់បំពេញចិត្តមនុស្ស នោះខ្ញុំមិនមែនជាបាវបម្រើរបស់ព្រះគ្រីស្ទទេ**» (*កាឡាទី ១:១០*) ។

- ត្រូវសុខចិត្តនឹងរងទុក្ខលំបាកដើម្បីព្រះគ្រីស្ទ ដូចព្រះអង្គបានរងទុក្ខលំបាកដើម្បីអ្នករួចហើយដែរ ៖ «**ដូច្នេះ ដែលព្រះគ្រីស្ទ ទ្រង់បានរងទុក្ខក្នុងសាច់ឈាមជំនួសយើងរួចហើយ នោះត្រូវឲ្យអ្នករាល់គ្នាមានគំនិតដូច្នោះដែរ**» (*១ពេត្រុស ៤:១*) ។

- បើអ្នកដឹងថា នឹងត្រូវគេបៀតបៀន ព្រោះតែមិនព្រមផឹកទេ នោះត្រូវរាប់វាជាព្រះពរវិញ ។ ព្រះយេស៊ូវមានបន្ទូលថា «**មានពរហើយ អស់អ្នកដែលត្រូវគេបៀតបៀនដោយព្រោះសេចក្តីសុចរិត ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ ។ អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខុសគ្រប់ទាំងសេចក្តីអាក្រក់ ពីអ្នករាល់គ្នា ដោយព្រោះខ្ញុំ ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌**» (*ម៉ាថាយ ៥:១០-១២*) ។

- កុំឲ្យរិះគន់លើបងប្អូនរួមជំនឿរបស់អ្នក ដែលជ្រើសផឹកស្រា ពីព្រោះអ្នកគ្មានឋានៈអ្វីនឹងវិនិច្ឆ័យដល់បាវបម្រើដទៃរបស់ព្រះអម្ចាស់បានឡើយ ៖ «**តើអ្នកជាអ្វីដែលនិន្ទាបាវបម្រើរបស់គេ អ្នកនោះឈរឬដួលក្តី នោះស្រេចនឹងចៅហ្វាយ** [*គឺព្រះអម្ចាស់*] **ទេតើ**» (*រ៉ូម ១៤:៤*) ។ ជាមួយគ្នានេះដែរ យើងក៏មិនត្រូវធ្វើអ្វីៗទាំងអស់ ដែលអាចនាំឲ្យគេជំពប់ដួលទៅក្នុងអំពើបាបឡើយ ដូចបានលើកឡើងក្នុងជំពូក ទី៧ រួចមកហើយ ។ នៅពេលក្រោយ បើសិនជាមានឱកាសដ៏ល្អត្រឹមត្រូវ នោះយើងអាចជួយពន្យល់គេដោយប្រើពាក្យសម្តីទន់ភ្លន់ ឲ្យចេះប្រព្រឹត្តអំពើដ៏ស័ក្តិសមទៅនឹងតម្លៃនៃឈើឆ្កាងរបស់អង្គព្រះគ្រីស្ទបាន ។
- ដូចគ្នានេះដែរ យើងក៏គ្មានសិទ្ធនឹងវិនិច្ឆ័យលើអ្នកមិនជឿឡើយ ។ ចៅក្រមរបស់មនុស្សលោកមានតែព្រះអម្ចាស់មួយព្រះអង្គគត់ ដូច្នេះ យើងត្រូវទុកឲ្យព្រះអង្គវិនិច្ឆ័យលើពួកគេវិញ (*ចោទិយកថា ៣២:៣៥*) ។ យើងមិនត្រូវមើលងាយអ្នកជឿពុទ្ធសាសនា ដែលផឹកស្រាខុសពីសីល ទី៥ ក្នុងជំនឿរបស់ពួកគេទេ ក៏មិនត្រូវពោលពាក្យក្រអឺតក្រទមអំពីជំនឿរបស់ខ្លួនដែរ ពីព្រោះ «**ព្រះ ទ្រង់ទាស់ទទឹងនឹងពួកមានឫកធំ តែទ្រង់ផ្តល់ព្រះគុណមកពួករាបសាវិញ**» (*យ៉ាកុប ៤:៦*) ។ ដូច្នេះ យើងត្រូវប្រកាន់យកចរិតសុភាពស្លូតបូតជានិច្ច ។

### *នៅពេលដែលយើងទៅចូលរួមក្នុងពិធី ៖*

- ត្រូវព្យាយាមទៅឲ្យលឿនបន្តិច ដើម្បីបានទៅដល់មុនពួកគេស្រវឹង ពីព្រោះនៅពេលពួកគេស្រវឹងហើយ នោះវារឹតតែពិបាក ព្រោះតែពួកគេនឹងបង្ខិតបង្ខំឲ្យផឹក ឬនិយាយចំអកឡកឡឺយដាក់អ្នករឹតតែខ្លាំងឡើងៗ ។
- ត្រូវព្យាយាមទៅជាមួយអ្នកជឿ ដែលមិនផឹកស្រាមួយ ឬពីរនាក់ទៀត ។ គេបង្ខិត

បង្ខំពីរ ឬបីនាក់ឲ្យផឹក ពិបាកជាងបង្ខិតបង្ខំអ្នកតែម្នាក់ឯង ។ វាក៏បង្ហាញឲ្យពួកគេឃើញថា មានមនុស្សមួយចំនួនទៀត ដែលសម្រេចចិត្តតមស្រាដូចគ្នាដែរ ។

- ត្រូវចៀសវាងទៅជាមួយអ្នកជឿ ដែលចង់ផឹកស្រាដែរ ដើម្បីកុំឲ្យកើតមានការបាក់បែកគ្នានៅមុខអ្នកមិនជឿ ឬមានគ្នាឯងបង្ខិតបង្ខំឲ្យផឹកស្រាខុសពីមនសិការរបស់ខ្លួន ។
- ដោយរៀបចំពាក្យសម្ដីទន់ភ្លន់ និងគួរសមស្រាប់ ត្រូវប្រាប់គេតាមត្រង់ថា "អរគុណបងណាស់ ! ខ្ញុំមិនផឹកស្រាទេ *ដោយសារជំនឿរបស់ខ្ញុំ*" ។ យើងមិនត្រូវយកលេសដូចជា "ខ្ញុំឈឺក្បាល" ទេ ។ បើអ្នកនិយាយបែបដូច្នេះ វាហាក់ដូចជាជំនឿរបស់ខ្លួនគ្មានតំលៃនោះឡើយ ។ ដូចគ្នានេះដែរ មិនត្រូវនិយាយអួតអាងច្រើនពន់ពេកទេ តែបើគេសួរអំពីជំនឿរបស់អ្នក នោះត្រូវហ៊ានឆ្លើយតបដោយអត្តចរិតសុភាព ( *១ពេត្រុស ៣:១៥* ) ។ អ្នកអាចរំឭកពួកគេដោយយកគួរសមថាអ្នកកាន់ពុទ្ធសាសនាមួយចំនួនក៏តមស្រាដែរ ។
- យើងមិនត្រូវខ្មាស ឬខ្លាចពួកគេសោះឡើយ ពីព្រោះការខ្នះខ្នែងគាប់ដល់ព្រះហឫទ័យព្រះអម្ចាស់ មិនមែនជាការទាបថោក ដែលគួរឲ្យខ្មាសនោះឡើយ ។
- ជាមួយគ្នានេះដែរ ទោះជាមានចិត្តអង់អាចក៏ដោយ ក៏ត្រូវទប់ចិត្ត ទប់មាត់ផងចុះ កុំឲ្យវាយឫកធំ ឬពោលពាក្យព្រហើនៗ ដូចជាខ្លួនប្រសើរជាងអ្នកដទៃឲ្យសោះ ។ « **ចិត្តឆ្មើងឆ្មៃរបស់មនុស្ស នឹងនាំឲ្យទាបថោកទៅ តែអ្នកណាដែលមានចិត្តសុភាពរាបទាប នោះនឹងបានកិត្តិសព្ទវិញ** » ( *សុភាសិត ២៩:២៣* ) ។
- បើអ្នកមិនព្រមផឹកស្រារបស់គេទេ នោះគេមុខជានឹងជឿថា អ្នកមិនចង់រាប់អានគេ ឬអ្នកប្រកាន់ខ្លួនថា ប្រសើរជាងអ្នកដទៃ ។ កុំទុកឲ្យពួកគេគិតអំពីអ្នកបែបដូច្នេះ

ឡើយ ។ តែត្រូវចេះដាក់ខ្លួនឲ្យរាបសា ហើយរកវិធីផ្សេងៗទៀត ដើម្បីបង្ហាញថា អ្នករាប់រក និងឲ្យតម្លៃលើពួកគេវិញ ។

- ដល់ពេលពួកគេស្រវឹងបន្តិចហើយ រួចចាប់ផ្តើមពោលពាក្យអាក្រក់ៗ នោះយើងត្រូវរកឱកាសដកខ្លួនដោយយកគួរសម ពីព្រោះ យើងចូលរួមក្នុងកិរិយាបែបនោះមិនបានសោះឡើយ ។ យើងជាតំណាងរបស់ព្រះដ៏ឧដុង្គឧត្តមបំផុត ដូច្នេះត្រូវតែយកកិរិយាដ៏ថ្លៃថ្នូរវិញ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ ។ បើសិនជាយើងជាប់នៅជាមួយពួកគេបន្តទៀត នោះមុខតែនឹងត្រូវបានកៀរយកទៅ ឲ្យចូលរួមក្នុងអំពើសៅហ្មងរបស់ពួកគេដែរ ។
- ពិធីចប់ហើយ នៅថ្ងៃក្រោយ យើងគួរតែរកឱកាសអរគុណដល់អ្នកទទួលភ្ញៀវដែលបានអញ្ជើញយើងចូលរួម ដើម្បីឲ្យគេដឹងថា យើងមានចិត្តដឹងគុណ ហើយឲ្យតម្លៃលើគេ ទោះជាមិនបានផឹកស្រារបស់គេក៏ដោយ ។

អ្នកនឹងឃើញថា លើកដំបូងដែលអ្នកបដិសេធ មិនព្រមផឹកស្រារួមជាមួយពួកគេទេនោះ គឺវាពិតជាពិបាកណាស់ ប៉ុន្តែ លើកក្រោយៗ នឹងបានកាន់តែស្រួលវិញ ។ មនុស្សមួយចំនួនប្រាកដជានឹងសើចចំអកដាក់អ្នក តែមនុស្សមួយចំនួនទៀតនឹងកោតសរសើរអ្នកវិញ ជាពិសេស បើពួកគេឃើញអ្នកបង្ហាញការគោរពដល់អ្នកដទៃព្រមទាំងអ្នកទទួលភ្ញៀវ ។ សំខាន់ជាងនេះឆ្ងាយណាស់ គឺថា នៅថ្ងៃដែលព្រះអម្ចាស់ជំនុំជំរះមនុស្សលោកទាំងអស់ អ្នកនឹងទទួលបានការសរសើរពីព្រះអង្គ ពីព្រោះបានចៀសចេញពីមាគ៌ានៃអំពើបាប ដោយគោរពកោតខ្លាចដល់ព្រះអម្ចាស់ រួមទាំងបាននាំឲ្យអ្នកដទៃសរសើរដល់ទ្រង់ទៀតផង ព្រោះតែឃើញទីបន្ទាល់ល្អរបស់អ្នក ក្នុងឈ្មោះជាកូនរបស់ព្រះអង្គ ។

# *ជំពូក ទី១២*
# *ក្ដីសង្ឃឹមសម្រាប់អស់អ្នកដែលជាប់ញៀនស្រា*

អ្នកដែលកំពុងតែជាប់ញៀនស្រាត្រូវមានសង្ឃឹមលើព្រះអម្ចាស់ឡើង ! ដោយសារព្រះអម្ចាស់មិនសព្វព្រះហឫទ័យឲ្យកូនរបស់ព្រះអង្គបានស្រវឹងស្រានោះឡើយ ដូច្នេះ ទ្រង់មុខតែនឹងជួយដល់កូនណាម្នាក់របស់ព្រះអង្គ ដែលមានចិត្តចង់ផ្ដាច់ស្រាជាមិនខាន ។ ព្រះអម្ចាស់ ទ្រង់នឹងផ្ដល់ព្រះគុណឲ្យទាន់ពេលដែលអ្នកត្រូវការ ដើម្បីជួយអ្នកយកបានជ័យជម្នះទៅលើការញៀននេះ បើសិនជាអ្នកសូមដោយចិត្តស្មោះសរចង់ទទួលយកព្រះគុណនោះពីព្រះអង្គពិតមែន ។ ព្រះអម្ចាស់មានព្រះបន្ទូលសន្យាថា «**គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកម្លាំងអញបានពេញខ្នាត ដោយសេចក្ដីកម្សោយ**» (*២កូរិនថូស ១២:៩*) ។ ដូច្នេះ អ្នកមិនត្រូវព្យាយាមផ្ដាច់ស្រាដោយខ្លួនឯងនោះទេ គឺត្រូវខិតខំព្យាយាមឲ្យអស់ពីកម្លាំងរបស់ខ្លួនពិតមែន តែអ្នកក៏ត្រូវរៀនចេះពឹងអាងលើព្រះគុណរបស់ព្រះអម្ចាស់ និងគ្រប់ទាំងជំនួយ ដែលទ្រង់ប្រទានមកផងដែរ រួមមានព្រះបន្ទូលរបស់ព្រះអង្គ ព្រះវិញ្ញាណដ៏បរិសុទ្ធដែលគង់នៅក្នុងចិត្តរបស់អ្នក និងបងប្អូនរួមជំនឿ ដែលរាប់អ្នកជាទីស្រឡាញ់ ។

ការញៀនស្រាប្រៀបដូចជាដុំថ្មដ៏ធ្ងន់មួយ ដែលកំពុងតែសង្កត់ទៅលើអ្នក ដោយលើកខ្លួនឯងមិនរួចសោះ តែបើហៅព្រះអម្ចាស់ និងបងប្អូនក្នុងក្រុមជំនុំមកជួយជាកម្លាំង ទើបអាចលើកវាចេញរួចបាន ។ ព្រះគ្រីស្ទពិតជាមានឫទ្ធានុភាព ល្មមនឹងអាចប្រគល់ជ័យជម្នះមកឲ្យអ្នកបាន ។ ហេតុនេះហើយបានជា សាវ័កប៉ុលមានប្រសាសន៍ថា «**ខ្ញុំអាចនឹងធ្វើ*<u>គ្រប់ទាំងអស់</u>*បាន ដោយសារព្រះគ្រីស្ទ ដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ**» (*ភីលីព ៤:១៣*) ។

យើងនឹងត្រូវស្រាល្បួង ជាពិសេស ក្នុងអំឡុងពេលដែលឃ្លានហួសពីកម្លាំងរបស់ខ្លួន ឬកើតមានទុក្ខព្រួយក្នុងជីវិត ចង់អស់សង្ឃឹមហើយ ។ *គឺនៅពេលនោះឯងដែលព្រះគ្រីស្ទមានព្រះហឫទ័យចង់ធ្វើជាព្រះអង្គសង្គ្រោះសម្រាប់អ្នក ។* ប្រសិនបើអ្នកគិតក្នុងចិត្តថា “ខ្ញុំនឹងផឹកតែបន្តិច” រួចផឹក គឺមានន័យថា ខ្លួនបានយកស្រាមកធ្វើជាព្រះសង្គ្រោះជំនួសព្រះគ្រីស្ទហើយ គឺជាអំពើអាក្រក់ណាស់ ស្មើនឹងការថ្វាយបង្គំរូបព្រះក្លែងក្លាយ ! ស្រាមិនអាចធ្វើជាព្រះពិតសម្រាប់អ្នកបានឡើយ ។

រីឯព្រះដ៏ពិតតែមួយព្រះអង្គវិញ ទ្រង់មានព្រះបន្ទូលសន្យាមកយើងថា ៖

> **គ្មានសេចក្ដីល្បួងណាកើតដល់អ្នករាល់គ្នា ក្រៅពីសេចក្ដីល្បួង ដែលត្រូវខាងមនុស្សលោកទេ រីឯព្រះ ទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឲ្យកើតមានសេចក្ដីល្បួងហួសកម្លាំងអ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន ។**
>
> *១កូរិនថូស ១០:១៣*

ក្នុងព្រះគម្ពីរវគ្គនេះបង្ហាញឲ្យឃើញច្បាស់លាស់ថា ព្រះជាម្ចាស់ ទ្រង់ស្មោះត្រង់ ហើយអ្នកណាដែលពឹងទៅលើព្រះអង្គ អ្នកនោះអាចយកជ័យជម្នះដោយផ្លូវវាង ដែលព្រះអង្គនឹងរៀបចំឲ្យ ។ ប្រសិនបើព្រះជាម្ចាស់មានព្រះបន្ទូលសន្យាថា ទ្រង់នឹងរៀបចំផ្លូវឲ្យចៀសរួច នោះយើងត្រូវស្វែងរកផ្លូវនោះជានិច្ចកុំបីខាន ។ យើងក៏ត្រូវរៀនឲ្យចេះវៀរចាក មិនព្រមប្រព្រឹត្តអំពើណាមួយ ដែលមានលទ្ធភាពអាចនឹងធ្វើឲ្យយើងក្លាយជាឈ្លើយសឹក ឲ្យបម្រើការញៀនបន្តទៀតនោះឡើយ ដោយប្ដេជ្ញាចិត្តដូចសាវ័កប៉ុលថា «**ខ្ញុំមិនព្រមចុះចូលក្នុងអំណាចនៃការណាមួយនោះសោះ**» ( *១កូរិនថូស ៦:១២* ) ។

សេចក្ដីទាំងនេះតំរូវឲ្យយើងផ្លាស់ប្ដូរទំលាប់ក្នុងជីវិតមួយចំនួន ដូចជាឧទាហរណ៍ខាងក្រោមនេះជាដើម ៖

- បើសិនជាពួកម៉ាកម្នាក់មិនព្រមឈប់បបួលយើងឲ្យផឹកស្រា នោះយើងត្រូវតែឈប់ដើរលេងជាមួយនឹងគេទៀតហើយ ដោយចិត្តមិនព្រមចាញ់អំណាចនៃការល្បួងឲ្យផឹកស្រាសារជាថ្មីម្តងទៀតឡើយ ។ កុំឲ្យភ្លេចសេចក្តីនេះ ដែលព្រះគម្ពីរថ្លែងប្រាប់មកយើងថា «**កុំឲ្យច្រឡំឡើយ ពីព្រោះពួកម៉ាកអាក្រក់តែងនឹងបង្ខូចកិរិយាល្អ**» ( *១កូរិនថូស ១៥:៣៣* ) ។
- ផ្ទុយទៅវិញ មានសារសំខាន់ណាស់ ដែលយើងកសាងឡើងនូវទំនាក់ទំនងជាមួយបងប្អូនក្រុមជំនុំ ដែលពួកគាត់អាចនឹងជួយដាស់តឿនយើងឲ្យប្រព្រឹត្តការល្អបាន ( *ហេព្រើរ ១០:២៤* ) ។
- ប្រសិនបើយើងមានទំលាប់ទិញស្រានៅហាងលក់ចាប់ហួយមួយកន្លែង ដែលយើងតែងតែឃើញនៅតាមផ្លូវក្នុងដំណើរត្រឡប់មកពីកន្លែងធ្វើការវិញ នោះយើងត្រូវតែវាងផ្លូវនោះជានិច្ច ហើយកាត់តាមតំបន់មួយផ្សេងទៀត ដើម្បីនឹងស្វែងរកផ្លូវវាង ដែលព្រះជាម្ចាស់បានរៀបចំឲ្យ ជំនួសផ្លូវចាស់ ។
- បើយើងមានទំលាប់ផឹកឲ្យស្រវឹងនៅរាល់ពិធីការ នោះត្រូវឲ្យមនុស្សម្នាក់ផ្សេងទៀតក្នុងគ្រួសារទៅជំនួសយើងវិញ កុំឲ្យត្រូវល្បួងណាមួយ ដែលមិនចាំបាច់ ។

យើងបានក្លាយជាអ្នកជាប់ញៀនស្រាបន្តិចម្តងៗ ដោយសារតែទំលាប់ដែលធ្លាប់ធ្វើតាំងពីយូរណាស់មកហើយ ។ ដូច្នេះ យើងត្រូវរំពឹងទុកថា ការផ្តាច់ស្រាមិនសម្រេចបានភ្លាមៗតែម្តងនោះឡើយ ។ ហេតុនេះហើយបានជា យើងនិយាយខាងលើនេះថា "ត្រូវផ្លាស់ប្តូរ*ទំលាប់*ក្នុងជីវិតមួយចំនួន" ដូច្នេះ ។ ការស្រេកឃ្លានស្រាមុខតែនៅជាប់ក្នុងខ្លួនអ្នកយូរ ហើយមានមនុស្សមួយចំនួន ដែលមិនអាចបំបាត់ការឃ្លានស្រាផងដែរ ។ តែព្រះជាម្ចាស់ ដែលទ្រង់មានព្រះជន្មគង់នៅរហូតដល់អស់កល្បជានិច្ច ទ្រង់ក៏ស្ថិតនៅជាប់នឹងអ្នករហូតតទៅដែរ ដរាបណាអ្នកទទួលបានជោគជ័យទៅលើ

ការរៀននេះ ។ ព្រះជាម្ចាស់ ទ្រង់មិនទុកអ្នកចោល ឬបោះបង់អ្នកចោលឡើយ ។ សូមពិចារណាមើលអំពីព្រះបន្ទូលសន្យាដ៏អស្ចារ្យរបស់ព្រះអង្គខាងក្រោមនេះ ៖

ព្រះនេត្រព្រះយេហូវ៉ាទតទៅចំពោះមនុស្សសុចរិត
ហើយព្រះកាណ៌ទ្រង់ក៏ប្រុងស្តាប់សំរែករបស់គេ
ព្រះភក្ត្រព្រះយេហូវ៉ាទាស់ទទឹងនឹងពួកអ្នក ដែលប្រព្រឹត្តអាក្រក់
ដើម្បីនឹងដកយកសេចក្តីនឹកចាំចំពោះគេពីផែនដីចេញ
ឯមនុស្សសុចរិត គេអំពាវនាវ ហើយព្រះយេហូវ៉ា ទ្រង់ទទួលស្តាប់
ទ្រង់ក៏ប្រោសគេឲ្យរួចពីគ្រប់សេចក្តីលំបាករបស់គេ
ព្រះយេហូវ៉ា ទ្រង់គង់ជិតបង្កើយនឹងអស់អ្នក ដែលមានចិត្តសង្រេង
ហើយទ្រង់ជួយសង្គ្រោះដល់អស់អ្នក ដែលមានវិញ្ញាណទន់ទាប
មនុស្សសុចរិតតែងតែកើតមានសេចក្តីលំបាកជាច្រើន
តែព្រះយេហូវ៉ា ទ្រង់ជួយឲ្យរួចពីសេចក្តីទាំងនោះ ។

*ទំនុកដំកើង ៣៤:១៥-១៩*

រីឯអ្នកណា ដែលត្រូវស្រាល្បួង តែយកជ័យជម្នះបាន ដោយធ្វើតាមអស់ទាំងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយពឹងអាងលើព្រះគុណរបស់ទ្រង់ អ្នកនោះប្រាកដជាមានពរហើយ ថែមទាំងនឹងទទួលបានរង្វាន់ដ៏ធំទៀត នៅថ្ងៃដែលព្រះគ្រីស្ទ ទ្រង់យាងត្រឡប់មកវិញ ។

មានពរហើយ មនុស្សណាដែលស៊ូទ្រាំនឹងសេចក្តីល្បួង ដ្បិតកាលណាត្រូវល្បួងលឃើញថាខ្ជាប់ខ្ជួនហើយ នោះនឹងទទួលបានមកុដនៃជីវិត ដែលព្រះអម្ចាស់ទ្រង់សន្យានឹងប្រទានឲ្យដល់អស់អ្នកណាដែលស្រឡាញ់ទ្រង់ ។

*យ៉ាកុប ១:១២*